







ខុមហ្វ្រែល COMFREL

ព្រឹត្តិបត្រ ខុមហ្វ្រែល

# អ្នកឃ្លាំមើល

NEAK KLOAMMEUL

លេខ ៤៣ ឆ្នាំទី១២ ចេញថ្ងៃទី១៥ ខែវិច្ឆកា ឆ្នាំ២០១០

## រំលោភសិទ្ធិអ្នកបោះឆ្នោតគឺរំលោភសិទ្ធិមនុស្ស



## មាតិកា


- *អធិប្បាយលេខនេះ៖* បញ្ជីឈ្មោះអ្នកបោះឆ្នោតនៅតែចោទជាបញ្ហាសម្រាប់ការបោះឆ្នោតនៅកម្ពុជា....... ១
- ហិរញ្ញវត្ថុគណបក្សនយោបាយនៅសហរដ្ឋអាមេរិក.................................... ៤
- ការបោះឆ្នោតជ្រើសរើសសភាជាន់ទាបនៅប្រទេសអាហ្វហ្គានីស្ថាន .............................. ៧
- ឃ្លាំមើលសភា និងតំណាងរាស្ត្រ........................................ ១២
- កាលប្បវត្តិព្រឹត្តិការណ៍សំខាន់ៗ ...................................... ១៩

# បញ្ជីឈ្មោះអ្នកបោះឆ្នោតនៅតែចោទជាបញ្ហា សម្រាប់ការបោះឆ្នោតនៅកម្ពុជា

អធិប្បាយលេខនេះ

បញ្ហាបញ្ជីឈ្មោះអ្នកបោះឆ្នោតបានបង្កើតឡើងនូវបញ្ហា និងធ្វើឱ្យមានការបាត់បង់នូវសិទ្ធិអ្នកបោះឆ្នោតរាប់សែនអ្នកនៅក្នុងអំឡុងនៃការបោះឆ្នោតកាលពីឆ្នាំ២០០៧ និង២០០៨កន្លងទៅនេះ។ រហូតមកដល់បច្ចុប្បន្ន បញ្ហានេះនៅតែជាចំណោទ ជាក្តីបារម្ភ និងក្លាយទៅជាប្រធានបទដ៏សំខាន់សម្រាប់ការត្រៀមរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ឆ្នាំ២០១២ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៣ខាងមុខនេះ ហើយដែលទាមទារឱ្យមានការកែលំអជាបន្ទាន់។


អ្នកបោះឆ្នោតពិបាករកឈ្មោះ

ចាប់តាំងពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០០៧មកភាពជឿជាក់របស់ ក្រុមអ្នកពាក់ព័ន្ធការងារបោះឆ្នោតទៅលើបញ្ជីបោះឆ្នោតមានការថយចុះ យ៉ាងខ្លាំង។ នៅក្នុងអំឡុងពេលបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រឆ្នាំ២០០៨ ការចុះឈ្មោះអ្នកបោះឆ្នោត និងការសំអាតបញ្ជីបោះឆ្នោតមានភាពមិនប្រក្រតី មួយចំនួន បើទោះបីមានការខិតខំប្រឹងប្រែងធ្វើឱ្យដំណើរការនេះមានភាពប្រសើរឡើងក៏ដោយ។ ឆ្លងតាមការ ស្រាវជ្រាវស្ទង់មតិ ក៏ដូចជាការពិភាក្សាទៅតាមវេទិកានានាដែលបានរៀបចំឡើងដោយអង្គការសង្គមស៊ីវិលដែល មានការងារពាក់ព័ន្ធទៅនឹងការសង្កេតការណ៍បោះឆ្នោតបានរកឃើញថា ភាគរយនៃអ្នកបានបោះឆ្នោតធៀបនឹង អ្នកមានសិទ្ធិបោះឆ្នោតទាំងអស់មានការថយចុះ ហើយក៏មានការថយចុះខ្លាំងនៅតំបន់មួយចំនួន(មានការថយចុះ ២០% បើធៀបទៅនឹងអ្នកបោះឆ្នោតឆ្នាំ២០០៣)។ មួយវិញទៀតបើយោងតាមលទ្ធផលបោះឆ្នោតរបស់ គណៈកម្មាធិការ ជាតិរៀចំការបោះឆ្នោត(គ.ជ.ប) បានបង្ហាញឱ្យឃើញថា ៧៥%នៃប្រជាពលរដ្ឋដែលមានសិទ្ធិ បោះឆ្នោតប្រមាណ ៨,១២លាននាក់ ក្នុងបញ្ជីឈ្មោះបោះឆ្នោតបានបោះឆ្នោត និងមាន២៥% គឺស្មើនឹងប្រមាណ ២លាននាក់ពុំបានបោះឆ្នោត នេះក៏ជាសញ្ញាមួយដែលបានបង្ហាញថាការចុះឈ្មោះបោះឆ្នោត និងការសំអាតបញ្ជីបោះឆ្នោតបានធ្វើឱ្យប៉ះពាល់ទៅលើសិទ្ធិអ្នកបោះឆ្នោត។ បញ្ហាទាំងនេះមានការចោទប្រកាន់យ៉ាងខ្លាំងទៅលើអ្នក ទទួលខុសត្រូវក្នុងការងារចុះបញ្ជី និងសំអាតបញ្ជីឈ្មោះអ្នកបោះឆ្នោត។ ចាប់តាំងពីក្រោយការបោះឆ្នោតឆ្នាំ ២០០៣ ការចុះឈ្មោះអ្នកបោះឆ្នោត និងការធ្វើបច្ចុប្បន្នបញ្ជីបោះឆ្នោតត្រូវអនុវត្តដោយប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនឃុំ សង្កាត់ផ្ទាល់ ហើយធ្វើឡើងជារៀងរាល់ឆ្នាំ គឺចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី២០ខែតុលា។

ទាំងគណបក្សនយោបាយមិនកាន់អំណាច និងសង្គមស៊ីវិលដែលធ្វើការពាក់ព័ន្ធនឹងការងារបោះឆ្នោតនេះ បានធ្វើការកត់សំគាល់ទៅលើការអនុវត្តការងាររបស់ ស្មៀនឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់ក្នុងការចុះឈ្មោះ និងលុបឈ្មោះអ្នកបោះឆ្នោត ថាមានភាពលំអៀង ឬមានការរើសអើងទៅលើអ្នកបោះឆ្នោតដែលគេអាចដឹងថាមាននិន្នាការមិនគាំទ្រគណបក្សកាន់អំណាច។ ការដែលតំរូវឱ្យមានអ្នកបោះឆ្នោតត្រូវទៅពិនិត្យបញ្ជីឈ្មោះជារៀងរាល់ឆ្នាំនេះក៏ជាបញ្ហាដែលបានលើកឡើងថាជាការដាក់ការទទួលខុសត្រូវទៅលើអ្នកបោះឆ្នោតជាជាងទៅលើអ្នក អនុវត្តការចុះឈ្មោះបោះឆ្នោត(មេឃុំ ចៅសង្កាត់ ស្មៀនឃុំ សង្កាត់ និងគ.ជ.ប)ក្នុងករណីមានការបាត់បង់សិទ្ធិ បោះឆ្នោត។ តាមរបាយការណ៍ស្រាវជ្រាវមួយរបស់អង្គការខុមហ្វ្រែល បានបង្ហាញឱ្យឃើញថា នៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៨ មានប្រជាពលរដ្ឋខ្មែរដែលមានសិទ្ធិបោះឆ្នោតប្រហែល ៤៤០.០០០ នាក់(ភាគច្រើននៃអ្នកទាំងនោះបានបោះឆ្នោតនៅក្នុងឆ្នាំ២០០៣ និង២០០៧) ពុំបានបោះឆ្នោតដោយសារបញ្ហា ផ្សេងៗដែលច្រើនជាករណីដែលអ្នកបោះឆ្នោតពុំអាចរកឈ្មោះ ឬពុំអាចរកការិយាល័យបោះឆ្នោតឃើញ។ ទន្ទឹមនឹង នេះអង្គការសង្កេតការណ៍បោះឆ្នោត និងគណបក្សនយោបាយមួយចំនួនមានការខ្វល់ខ្វាយទៅលើភាពមិនប្រក្រតី ទាក់ទិនទៅនឹងការចេញទំរង់១០១៨ (ឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់ការបោះឆ្នោត)។ នៅក្នុងករណីនេះមាន ការចោទប្រកាន់ពីសំណាក់គណបក្សមិនកាន់អំណាច ថាកន្លងមក មេឃុំ ចៅសង្កាត់ មួយចំនួនបានចេញទំរង់ ១០១៨ទៅដល់អ្នកដែលមិនមានសិទ្ធិបោះឆ្នោតជាពិសេស អ្នកដែលមាននិន្នាការគាំទ្រគណបក្សកាន់អំណាច។ ករណីនេះដែរ គ.ជ.ប ក៏មិនមានលទ្ធភាពក្នុងការបង្ហាញពីចំនួន ទំរង់១០១៨ដែលបានចេញនៅក្នុងពេលបោះឆ្នោត






វេទិការស្តីពីការបោះឆ្នោត និងប្រជាធិបតេយ្យនៅខេត្តព្រៃវែង រៀបចំឡើងដោយខុមហ្វ្រែល


ថ្នាក់ដឹកនាំ គ.ជ.ប

ឆ្នាំ២០០៨។ តាមការស្ទៀបស្ទង់មតិក្នុងវេទិកាស្តីពីការបោះឆ្នោតនិងប្រជាធិបតេយ្យបានរកឃើញថា មានទស្សនៈពីរផ្សេងគ្នាចំពោះការចេញទម្រង់ ១០១៨ ដោយក្នុងនោះ ទស្សនៈមួយបានស្នើឲ្យលុបចោលនូវទម្រង់១០១៨ តម្រូវឲ្យឈប់យកប្រើប្រាស់ក្នុងពេលបោះឆ្នោតខាងមុខ ព្រោះមានបញ្ហាច្រើនលើកមកហើយ។ ចំណែកមតិមួយទៀតបានផ្តួចផ្តើមឲ្យមានការរក្សាទុកទម្រង់ ១០១៨ ដដែល តែត្រូវមានវិធានការពង្រឹងការគ្រប់គ្រង ចំពោះអ្នកចេញលិខិតនេះ និងថែរក្សាគល់បញ្ជីនៃការចេញលិខិត១០១៨ ព្រោះសំអាងហេតុផល ទម្រង់ ១០១៨ប្រើប្រាស់បានសម្រាប់តែការបោះឆ្នោត ហើយភាគច្រើននៃពលរដ្ឋកម្ពុជា មានការលំបាកក្នុងការរក្សាឯកសារឲ្យបានគ្រប់គ្រាន់ដើម្បីបោះឆ្នោត។

ជុំវិញបញ្ហាទាំងនេះមាននិន្នាការរួមគ្នាមួយពីគ្រប់ភាគីពាក់ព័ន្ធ គឺត្រូវតែមានការកែលំអនូវបញ្ជីឈ្មោះអ្នកបោះឆ្នោតជាចាំបាច់។

ក្នុងកិច្ចប្រជុំប្រកាសលទ្ធផលបណ្តោះអាសន្ននៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ ២០១០ កាលពីថ្ងៃទី ១២ តុលា នៅឯស្នាក់ការកណ្តាល គ ជ ប រាជធានីភ្នំពេញ គណបក្សនយោបាយជាច្រើនបានទទូចឱ្យ គ ជ ប កែប្រែប្រព័ន្ធរៀបចំបញ្ជីចុះឈ្មោះបោះឆ្នោតបច្ចុប្បន្នដើម្បីជៀសវាងការបាត់ឈ្មោះ មានឈ្មោះស្ទួន និងមិនឱ្យប្រជាពលរដ្ឋខាត់បង់ពេលវេលាច្រើនក្នុងការពិនិត្យបញ្ជីចុះឈ្មោះច្រើនដង ហើយបានណែនាំឱ្យ គ ជ ប ប្រើប្រាស់កុំព្យូទ័រ ដើម្បីបញ្ចូលទិន្នន័យ និងចំណេញពេលវេលា តែមន្ត្រីជាន់ខ្ពស់ គ ជ ប មានឯកឧត្តម **ទេព នីថា** និងលោកជំទាវ **ស៊ិន ជុំបូ** បានបកស្រាយថា ក្នុងស្ថានភាពបច្ចុប្បន្ននេះ ប្រទេសកម្ពុជាមិនអាចកែប្រែប្រព័ន្ធបញ្ជីចុះឈ្មោះបោះឆ្នោតឱ្យស្របទៅតាមបច្ចេកវិទ្យាជឿនលឿនបានទេ ព្រោះ គ ជ ប ខ្វះខាតថវិកាទិញសម្ភារៈ។

**ឆ្លងកាត់តាមការពិភាក្សាមួយចំនួនបានប្រមូលផ្តុំបាននូវអនុសាសន៍មួយចំនួនដូច ខាងក្រោមៈ**

- ដើម្បីធ្វើឱ្យប្រសើរឡើងនូវការ ចុះឈ្មោះអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត ការចុះឈ្មោះអ្នកបោះឆ្នោត និងការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតប្រចាំឆ្នាំដោយក្រុមប្រឹក្សាឃុំ សង្កាត់ គួររក្សាទុកដដែល។ ក្នុងករណីនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវមានឯកសារបញ្ជាក់គ្រប់គ្រាន់មុននឹងធ្វើបច្ចុប្បន្នភាព ឬលុបឈ្មោះអ្នកបោះឆ្នោត ដែលផ្លាស់ប្តូរទីលំនៅទៅឃុំ ផ្សេង ឬស្លាប់។ ដោយសារតែការបោះឆ្នោតត្រូវបានធ្វើឡើងជារៀងរាល់ ៥ ឆ្នាំ ដូច នេះ នៅក្នុងអំឡុងឆ្នាំបោះឆ្នោត គជប ត្រូវសហការជាមួយប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានសមាសភាពចំនួនពីររូប (មកពីគណបក្សនយោបាយផ្សេងគ្នា) ស្មៀនឃុំ សង្កាត់ និងអាជ្ញាធរមូលដ្ឋាន ផ្សេងៗទៀតត្រូវទទួលខុសត្រូវរៀបចំការចុះឈ្មោះអ្នកបោះឆ្នោត និងធ្វើបច្ចុប្បន្នភាព បញ្ជីបោះឆ្នោតពិសេសមួយ សម្រាប់ការបោះឆ្នោត។ រយៈពេលការចុះឈ្មោះអ្នកបោះឆ្នោត និងធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត ពិសេសនេះ គួរបន្ថែមដល់ ១២០ ថ្ងៃ ដើម្បីឱ្យប្រជាពលរដ្ឋមានពេលវេលាច្រើនចុះឈ្មោះបោះឆ្នោត និងពិនិត្យកែតម្រូវទិន្នន័យក្នុងបញ្ជីបោះឆ្នោត។ គជប គួរតែងតាំងបុគ្គលិករបស់ខ្លួនជាប្រធាន/អ្នកគ្រប់គ្រងក្នុងការចុះឈ្មោះអ្នកបោះឆ្នោត ថ្នាក់ឃុំ សង្កាត់។ យុទ្ធនាការថ្នាក់ជាតិត្រូវតែធ្វើឡើងដើម្បីផ្សព្វផ្សាយ និងជម្រុញអ្នកបោះឆ្នោត



បញ្ជីឈ្មោះមានខ្មោច

ឱ្យទៅចុះឈ្មោះ បោះឆ្នោត ពិនិត្យឈ្មោះ និងកែតម្រូវព័ត៌មានក្នុងបញ្ជីបោះឆ្នោតក្នុងករណីខុសពីឯកសារ អត្តសញ្ញាណពិតប្រាកដ របស់ខ្លួន។ យុទ្ធនាការនេះ អាចធ្វើឡើងដោយ គជប គណបក្សនយោបាយ រាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល ឬ/ និងភាគីពាក់ពន្ធ័ការបោះឆ្នោតនានា។ លើសពីនេះទៅទៀត អង្គការសង្កេតការណ៍បោះឆ្នោត និងគណបក្សនយោបាយ អាចធ្វើការអង្កេតទៅលើដំណើរការចុះឈ្មោះអ្នកបោះឆ្នោត និងការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតពិសេស នេះ។

- ការប្រគល់ការទទួលត្រូវការចុះឈ្មោះបោះឆ្នោត និងធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតនេះទៅឱ្យ គជប ក៏ ដោយសារតែតាមលទ្ធផលអង្កេតបង្ហាញថា អ្នកមានសិទ្ធិបោះឆ្នោតជាង ៥០ % (ក្នុងចំណោមអ្នកជួបបញ្ហា) មាន ការជឿជាក់



*សកម្មជនខុមហ្វ្រែលសម្ភាសន៍ជាមួយអ្នកមានសិទ្ធិបោះឆ្នោត*

ទៅលើ ការងាររបស់ គជប តែមួយគត់។ ហើយក្នុងការអង្កេតនៅក្នុងការបោះឆ្នោតឆ្នាំ ១៩៩៨ និង ២០០២ បង្ហាញថា ការចុះឈ្មោះបោះឆ្នោត និងធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតដែលធ្វើឡើងដោយ គជប គឺមាន ភាពត្រឹមត្រូវច្រើនជាងប្រពន្ធ័បច្ចុប្បន្ន។

- អង្គការមិនមែនរដ្ឋាភិបាលដែលជាស្ថាប័នឯករាជ្យគួរធ្វើសវនកម្មបញ្ជីបោះឆ្នោត ដើម្បីផ្តល់ព័ត៌មានពី ភាពត្រឹមត្រូវនៃបញ្ជីបោះឆ្នោត មុននឹងមានការចុះឈ្មោះបោះឆ្នោត និងការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតពិសេស។ ព័ត៌មាននៅក្នុងបញ្ជីបោះឆ្នោត (ឈ្មោះ ថ្ងៃខែឆ្នាំកំណើត ភេទ) គួរតែត្រូវធ្វើការផ្ទៀងផ្ទាត់ជាមួយនឹងអត្ត សញ្ញាណប័ណ្ណដែលចេញដោយក្រសួងមហាផ្ទៃ។ គជប ត្រូវប្រើព័ត៌មាននេះដើម្បីផ្ទៀងផ្ទាត់ និងធ្វើបច្ចុប្បន្នភាព បញ្ជីបោះឆ្នោត។ ទោះបីយ៉ាងណា គជប ត្រូវធ្វើទំនាក់ទំនងជាមួយអ្នកចុះឈ្មោះបោះឆ្នោតដែលព័ត៌មានរបស់គាត់ ត្រូវការកែតម្រូវ ឬបច្ចុប្បន្នភាព។ ជាមួយគ្នានេះ ក្រសួងមហាផ្ទៃគួរតែសម្អាតទិន្នន័យរបស់ខ្លួនជាមុនសិន ដោយ មានម្ចាស់ជំនួយមួយចំនួនដូចជា កម្មវិធីអភិវឌ្ឍន៍ប្រជាជាតិ (UNDP) កំពុងតែព្យាយាម គាំទ្រគម្រោងមួយដែល ធ្វើទិន្នន័យ អត្តសញ្ញាណតាមជីវសាស្ត្រ។

ប្រសិនបើការធ្វើសវនកម្មបញ្ជីបោះឆ្នោតរកឃើញថា ភាពត្រឹមត្រូវនៃបញ្ជីបោះឆ្នោតនៅក្រោម ៩០ % (ទិន្នន័យមិនត្រឹមដូចជាឈ្មោះស្ទួន និងឈ្មោះខ្មោច) គជប ដោយសហការជាមួយប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានចំនួនពីររូប (មកពីគណបក្សនយោបាយផ្សេងគ្នា) ស្មៀនឃុំ សង្កាត់ និងអាជ្ញាផ្សេងៗទៀត ត្រូវទទួលខុសត្រូវសម្អាតបញ្ជីបោះឆ្នោត។ នីតិវិធីនៃការសម្អាតបញ្ជីឆ្នោតត្រូវតែធ្វើការកែប្រែ។ គជប គួរតែប្រើប្រាស់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងបោះឆ្នោតចុងក្រោយ ហើយរកឈ្មោះអ្នកដែលមិន បានបោះឆ្នោត។ ដូចនេះ គជប ត្រូវផ្តោតការយកចិត្តទុកដាក់តែជនដែលមិនបានបោះឆ្នោតដែលធ្វើឡើងក្រោយគេ បានហើយ ដោយមិនបាច់គិតពីអ្នកដែលបានបោះឆ្នោតនោះទេ។

- អ្នកបោះឆ្នោតម្នាក់ៗត្រូវតែមានប័ណ្ណព័ត៌មានបោះឆ្នោតដើម្បីដោះស្រាយឧបសគ្គធំៗនានានៅ ការិយា ល័យបោះឆ្នោតដែលជួបបញ្ហារកឈ្មោះ ឬការិយាល័យបោះឆ្នោតរបស់ខ្លួនមិនឃើញ។ ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ត្រូវបានផលិតដោយមានអ៊ុតប្លាស្ទិក ហើយត្រូវមានព័ត៌មានអ្នកបោះឆ្នោត ជាពិសេសការិយាល័យ នឹងមណ្ឌលបោះឆ្នោត "ជាអចិន្ត្រៃយ៍។ អ្នកបោះឆ្នោតត្រូវរក្សាប័ណ្ណព័ត៌មានទុកដូចជា ប័ណ្ណដទៃទៀតដែរ។ ព័ត៌មានអ្នក បោះឆ្នោតអាចដូរបាន ក្នុងករណីដែលអ្នកបោះឆ្នោត ផ្លាស់ប្តូរលំនៅដ្ឋានទៅឃុំ ផ្សេងទៀត។ គជប ត្រូវរៀបចំ បញ្ជីបោះឆ្នោតនៅការិយាល័យ បោះឆ្នោតណាដែលមានបញ្ហា (ឧទាហរណ៍ រៀបតាមអក្ខរក្រម ឬលេខកូដអ្នកបោះឆ្នោត លេខកូដការិយាល័យ) ហើយការផ្លាស់ប្តូរទាំងនេះត្រូវតែជូនដំណឹងដល់អ្នកបោះឆ្នោត។ ជាងនេះទៅ ទៀត ដោយឧបសគ្គចម្បងនានាដែលនាំឱ្យបោះឆ្នោតមិនបាន គឺទាក់ទងទៅនឹងការរកឈ្មោះ ឬការិយាល័យមិន ឃើញ (៥៦% នៃចម្លើយ) ហើយដោយគិតទៅលើអ្នកបោះឆ្នោតប្រមាណ ៩ % ដែលមិនបានទទួលប័ណ្ណព័ត៌មាន អ្នកបោះឆ្នោត នោះការចែកប័ណ្ណព័ត៌មានគួរតែត្រូវធ្វើឡើងដោយ គជប ដោយសហការ ជាមួយប្រធានក្រុម ប្រឹក្សាឃុំ សង្កាត់ សមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ ដោយមានចំនួនពីររូប (មកពីគណបក្សនយោបាយផ្សេងគ្នា) ស្មៀនឃុំ សង្កាត់ និងអាជ្ញាធរមូលដ្ឋានផ្សេងៗទៀតដែលអ្នកបោះឆ្នោតចង់ឱ្យធ្វើកិច្ចការនេះ។ ហើយត្រូវធានាថា អ្នកបោះឆ្នោតដែលបានចុះឈ្មោះទាំងអស់ត្រូវទទួលបានប័ណ្ណព័ត៌មានអ្នកបោះឆ្នោត។

- ដោយមានការគាំទ្រពីម្ចាស់ជំនួយ ក្រសួងមហាផ្ទៃ គួរព្យាយាមឱ្យអស់លទ្ធភាពដើម្បីចេញ និងចែកអត្ត សញ្ញាណប័ណ្ណខ្មែរដល់ប្រពលរដ្ឋកម្ពុជា ឱ្យបាន យ៉ាងយូរត្រឹមឆ្នាំ២០១១។ ប្រសិនបើអាចធ្វើបាន (ដោយអត្ត សញ្ញាណសញ្ជាតិខ្មែរចេញឱ្យពលរដ្ឋកម្ពុជាដែលមានអាយុចាប់ពី ១៥ ឆ្នាំ ឡើងទៅ) នោះអ្នកបោះឆ្នោតថ្មីទាំងអស់ នឹងមានឯកសារ បញ្ជាក់អត្តសញ្ញាណដើម្បីបោះឆ្នោតនៅថ្ងៃបោះឆ្នោត៕



ករណីសិក្សា

# ហិរញ្ញវត្ថុគណបក្សនយោបាយ នៅសហរដ្ឋអាមេរិក

ប្រព័ន្ធច្បាប់បញ្ញត្តិហិរញ្ញវត្ថុពេលឃោសនាបោះឆ្នោតនៅអាមេរិក គឺផ្តោតយ៉ាងសំខាន់ទៅ លើការចង់ឲ្យមានការដាក់បង្ហាញជាសាធារណៈឲ្យបានពេញលេញ និងត្រឹមត្រូវនៃការចំណាយ និងមូលនិធិដែលរកបានដោយបេក្ខជនសម្រាប់តំណែងនយោបាយ និងគណៈកម្មការហិរញ្ញវត្ថុរបស់ពួកគេ ដែលមានគណបក្សនយោបាយ និងគណៈកម្មាធិការប្រព្រឹត្តិកម្មនយោបាយឯករាជ្យ។ នៅក្នុងប្រពន្ធ័នេះ មានបញ្ហាជាច្រើនបានកើតមានឡើងនៅក្នុងកំឡុងពេល២០ឆ្នាំចុងក្រោយមកនេះ ដែលភាគច្រើនទាក់ទងជាមួយ និងការផ្តល់មូលនិធិសម្រាប់ឃោសនាជាប្រាក់ទន់(Soft money) និងការផ្សព្វផ្សាយការតស៊ូមតិ។ រាល់បញ្ហាទាំងនេះ បាននាំឲ្យមានការបើកស៊ើបអង្កេតជា បន្តបន្ទាប់ភ្លាមៗ ទៅក្នុងសកម្មភាពនៃគណបក្សនយោបាយសំខាន់ៗទាំងពីរ និងកំណែទម្រង់ បទប្បញ្ញត្តិថ្មី នៅក្នុងសភាថ្នាក់សហពន្ធ័ និងថ្នាក់រដ្ឋ។



## ប្រពន្ធ័ដំណើរការនៃប្បញ្ញត្តិហិរញ្ញវត្ថុពេលឃោសនា



*ប្រធានាធិបតីអាមេរិកបារ៉ាក់អូបាម៉ា*

នៅប្រទេសអាមេរិក មានការអភិវឌ្ឍន៍ប្រពន្ធ័ស្ថាប័នសម្រាប់គ្រប់គ្រងទៅលើការផ្តល់នូវមូលនិធិ យ៉ាងល្អប្រសើរនៃយុទ្ធនាការឃោសនាបោះឆ្នោតសហពន្ធ័។ ការឃោសនាបោះឆ្នោតនៃរដ្ឋខុសៗគ្នា និងនៅតាមថ្នាក់តំបន់ត្រូវបានប្រព្រឹត្តទៅដោយអនុលោមទៅតាមច្បាប់របស់រដ្ឋ។

មូលដ្ឋានច្បាប់គ្រឹះ ដែលប្បញ្ញត្តិពីហិរញ្ញវត្ថុឃោសនាបោះឆ្នោតសហពន្ធ័នៅប្រទេសអាមេរិក គឺច្បាប់ស្តីពីយុទ្ធនាការឃោសនាបោះឆ្នោតសហពន្ធ័ឆ្នាំ១៩៧២ ។ ដោយអនុលោមទៅតាមការធ្វើវិសោធនកម្មនៅឆ្នាំ១៩៧៤នៃច្បាប់នេះ ស្ថាប័នឯករាជ្យមួយត្រូវបានបង្កើតឡើង គឺគណៈកម្មការបោះឆ្នោតសហពន្ធ័ (Federal Election Commission) ដែលមានគោលបំណងពង្រឹងនូវការសង្កេតការណ៍នៃច្បាប់បោះឆ្នោតសហពន្ធ័ និងជាជំនួយក្នុងការធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងរដ្ឋបាលនៃកម្មវិធីការផ្តល់ហិរញ្ញវត្ថុពីរដ្ឋ។

បន្ទាប់ពីតុលាការជាន់ខ្ពស់អាមេរិក បានពិចារណារឿងក្តីមួយរួចមក (Buckley v. Valeo) នៅឆ្នាំ១៩៧៦សភាអាមេរិកបានផ្តើមនូវវិសោធនកម្មមួយនៃច្បាប់នេះដែលបានអនុម័តនៅឆ្នាំ១៩៧៩ ។ ការធ្វើវិសោធនទាំងនោះ ត្រូវបានអនុម័តដើម្បីកែលម្អនូវដំណើរការធ្វើរបាយការណ៍ និងបង្កើននូវតួនាទីនៃគណបក្សនយោបាយ។ ច្បាប់នេះបានផ្តល់ឲ្យមាន៖



ការផ្សាយរបស់គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌

1. ការបោះពុម្ពផ្សាយនៃរបាយការណ៍ចំណូល និងចំណាយទៅឲ្យរដ្ឋបាលឃោសនាបោះឆ្នោតសហព័ន្ធ។
2. ការដាក់ដែនកំណត់ និងហាមប្រាមនៃការបង់ថ្លៃ និងចំណាយសម្រាប់រដ្ឋបាលបោះឆ្នោតសហព័ន្ធ។
3. ហិរញ្ញវត្ថុពីរដ្ឋ សម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតនៃការបោះឆ្នោតប្រធានាធិបតី អាមេរិក។


អតីតប្រធានាធបតីអាមេរិក និន សុន

ដោយអនុលោមទៅតាមច្បាប់ គណៈកម្មាធិការរបស់បេក្ខជន គណៈកម្មាធិការរបស់គណបក្សនយោបាយ និងគណៈកម្មាធិការប្រព្រឹត្តិកម្មនយោបាយ ត្រូវបានតម្រូវឲ្យបញ្ជូននូវរបាយ ការណ៍តាមរយៈពេលមួយ អំពី ការទទួល និង ការចំណាយហិរញ្ញវត្ថុ។ ឧទាហរណ៍ បេក្ខជនទាំងអស់ត្រូវបានតម្រូវឲ្យផ្តល់នូវបញ្ជីឈ្មោះនៃគណៈកម្មាធិការប្រព្រឹត្តិកម្មនយោបាយ និងគណៈកម្មាធិការបក្សនីតិបុគ្គល និងឯកជនទាំងអស់ ដែលបានផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ពួកគេលើសពី$២០០ក្នុង១ឆ្នាំ។

ដែនកំណត់សម្រាប់ចំនួននៃការបរិច្ចាគដោយស្មគ្រ័ចិត្ត ត្រូវបានបង្កើតឡើងដាច់ដោយឡែក ពីគ្នាសម្រាប់បុគ្គលឯកជនគណៈកម្មាធិការនយោបាយ និងគណៈកម្មាធិការនយោបាយដែលគាំទ្រ បេក្ខជនច្រើននាក់។ ចំនួនទាំងនោះខុសៗគ្នាគឺអាស្រ័យទៅលើ ថាតើការបរិច្ចាគនេះសម្រាប់អ្នកណា? ការបរិច្ចាគពីបុគ្គលឯកជន គឺមិនអាចលើសពី៖

– $១០០០ដែលផ្តល់ទៅឲ្យបេក្ខជន ឬគណៈកម្មាធិការបេក្ខជនសម្រាប់ការឃោសនាបោះឆ្នោតមួយជុំ។
– $២០០០០ក្នុងកុំឡុងពេល១មួយឆ្នាំប្រតិទិន ដែលផ្តល់ឲ្យគណៈកម្មាធិការនយោបាយដែលបានបង្កើតឡើង និងកំពុងត្រូវបានគេថែរក្សាដោយគណបក្សនយោបាយជាតិខ្លះៗ ហើយមិនមែនរបស់បេក្ខជនទេ។
– $៥០០០ក្នុងកុំឡុងពេល១ឆ្នាំប្រតិទិន ដែលផ្តល់ទៅឲ្យគណៈកម្មាធិការនយោបាយដទៃណាមួយ។

បុគ្គលម្នាក់មិនអាចបរិច្ចាគលើសពី$២៥០០០បានទេ សម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតក្នុងមួយឆ្នាំប្រតិទិន។

សាជីវកម្មសហជីពពាណិជ្ជកម្មអ្នកធ្វើកិច្ចសន្យាជាមួយរដ្ឋាភិបាលសហព័ន្ធ និងជនបរទេស មិនត្រូវបានអនុញ្ញាតឲ្យធ្វើការបរិច្ចាគ ឬចំណាយជួយបេក្ខជនសហព័ន្ធទេ។ វិធានការនៃច្បាប់ជាច្រើនដូចជាច្បាប់ស៊ីវិល ច្បាប់រដ្ឋបាល និងច្បាប់ឧក្រិដ្ឋកម្មត្រូវបានយកមកប្រើប្រាស់ដើម្បីពង្រឹងនូវភាពតឹងរ៉ឹង ដែលបានដាក់ទៅលើការចូលរួមការបោះឆ្នោតទាក់ទងទៅនឹងការផ្តល់មូលនិធិឃោសនាបោះឆ្នោតសហព័ន្ធ។ វិធានការទាំងនេះត្រូវបានអនុវត្តដោយគណៈកម្មការបោះឆ្នោតសហព័ន្ធ និងក្រសួងយុត្តិធម៌។

## ហិរញ្ញវត្ថុឃោសនាក្នុងការចៀសវាងបទប្បញ្ញត្តិដែលមានស្រាប់

នៅក្នុងការអនុវត្តន៍គណបក្សនយោបាយ និងបេក្ខជនអាចបង្កើនចំនួននៃប្រភពហិរញ្ញវត្ថុរបស់ខ្លួន ហើយទទួលបានការផ្តល់នូវមូលនិធិយ៉ាងច្រើនលើសលប់ សម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតរបស់ពួកគេ។ ពួកគេធ្វើយ៉ាងនេះបានដោយមិនបំពានច្បាប់ទេ គឺគេបានប្រើភាពមានចន្លោះប្រហោងនៅក្នុងច្បាប់ ក្នុងការស្វែងរកនូវមូលនិធិបន្ថែមទៀត ដែលអាជ្ញាធរមិនដាក់ទណ្ឌកម្មគេបានទេ។





**បញ្ហាលុយទន់** (Soft money)

លុយទន់ គឺជាប្រាក់ដែលរកបាន និងចំណាយនៅក្រៅក្របខ័ណ្ឌដែលបានហាមនៅក្នុងច្បាប់បោះឆ្នោតសហព័ន្ធ។ នៅប្រទេសអាមេរិកលុយទន់នេះបានដើរតួនាទីយ៉ាងធំធេងនៅក្នុងយុទ្ធនាការ ឃោសនាបោះឆ្នោតសហព័ន្ធ។ តាមច្បាប់ ប្រាក់ទាំងនេះត្រូវបានប្រគល់ទៅឲ្យគណៈកម្មាធិការជាតិនៃគណបក្សនយោបាយ ដែលបានបង្កើតឡើងនៅថ្នាក់រដ្ឋ។ វាមិនមានគោលបំណងសម្រាប់ផ្តល់នូវមូលនិធិក្នុងការយុទ្ធនាការឃោសនាដោយផ្ទាល់ទេ ប៉ុន្តែត្រូវបានប្រើប្រាស់សម្រាប់សេចក្តីត្រូវការ របស់គណបក្ស។ ដូច្នេះ វាអាចបង្កើតឲ្យមានការប្រើប្រាស់ដោយប្រយោលសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត។ ជាទូទៅ លុយទន់នេះត្រូវបានគេប្រើប្រាស់សម្រាប់លើកសរសើរពីគុណសម្បត្តិនៃគណបក្សនយោបាយណាមួយ។

ច្បាប់បានហាមប្រាមសាជីវកម្មធនាគារ និងសហជីពពាណិជ្ជកម្មក្នុងការបរិច្ចាគលុយទៅកាន់មូលនិធិបោះឆ្នោតរបស់បេក្ខជន ហើយធ្វើការបរិច្ចាគដោយឯករាជ្យដើម្បីសម្របសម្រួលការបោះឆ្នោតនៃបេក្ខជនជាក់លាក់ណាមួយ ប៉ុន្តែគ្មានអ្វីហាមប្រាមពួកគេមិនឲ្យដាក់លុយមួយចំនួនធំសម្រាប់ការប្រើប្រាស់របស់គណបក្សឡើយ។

## ការផ្សព្វផ្សាយមុនពេលការបោះឆ្នោត

ពេលបោះឆ្នោតសភាសហព័ន្ធនៅឆ្នាំ១៩៩៦ បានបង្ហាញឲ្យឃើញពីវិធីមួយទៀត ដែលមិនបានបញ្ញត្តិនៅក្នុងច្បាប់ ស្តីពីហិរញ្ញវត្ថុឃោសនាពេលបោះឆ្នោត ដែលវិធីនោះបានប៉ះពាល់ជាអវិជ្ជមានយ៉ាងខ្លាំង ទៅលើប្រព័ន្ធទាំងមូលនៃវិធានការគ្រប់គ្រងហិរញ្ញវត្ថុ គឺបញ្ហាផ្សព្វផ្សាយ ការតស៊ូមតិ។ យោងទៅតាមការអនុវត្តន៍នេះបុគ្គល និងក្រុមឯករាជ្យដែលបានគាំទ្រក្នុងរឿងនយោបាយណាមួយ អាចចំណាយលុយទៅលើការផ្សព្វផ្សាយរឿងនយោបាយរបស់ពួកគេតាមTV និងសារព័ត៌មាន និងតាមខិត្តប័ណ្ណផ្សេងៗ។ លុយទាំងនេះមិនបានផ្តល់ទៅឲ្យគណបក្សនយោបាយទេ ហើយក៏មិននៅក្រោមច្បាប់គ្រប់គ្រងរបស់សហព័ន្ធដែរ។ យោងតាមរបាយការណ៍ស្រាវជ្រាវពីឆ្នាំ១៩៩៥ដល់ឆ្នាំ១៩៩៦ មានក្រុមចំនួន២០ក្នុងចំណោម៣០ក្រុម បានចំណាយមិនតិចជាង$៥០លាន ឬអាច$១០០លានទៅលើបញ្ហាទាំងនោះ។ សកម្មភាពនៃក្រុមទាំងនោះ ត្រូវបានសម្របសម្រួលដោយអ្នកគាំទ្របេក្ខជន។



**ការផ្សាយសម្លេងសង្គមស៊ីវិល**

»»»ផ្សាយផ្ទាល់ ៖ **រាល់ថ្ងៃច័ន្ទ ដល់ ថ្ងៃអាទិត្យ ចាប់ពីម៉ោង ៧. ៣០ នាទី ដល់ ម៉ោង ៨.៣០ នាទីព្រឹក**
»»»តាមរយៈ ៖ **វិទ្យុ** FM 105 MHz (**ភ្នំពេញ**), FM 90 MHz (**ភ្នំពេញ**),
»»»ផ្សាយបន្តទៅតាមបណ្តាខេត្ត ៖ FM 90.25 MHz (**បាត់ដំបង**),
FM 88.5 MHz (**កំពង់ធំ**)
»»»ចាក់ផ្សាយនៅវិទ្យុអង្គរដ្ឋា ខេត្ត **សៀមរាប** ពីម៉ោង១២:៣០ ដល់ ១៣:០០ FM 95.5 MHz
»»»ចូលរួមបញ្ចេញមតិយោបល់ ៖ 023 88 57 45, 016 54 43 98, 012 43 34 37
»»»ផ្ញើសារជាអក្សរ (SMS) ៖ 017 91 92 80
»»»អ៊ីម៉ែល ៖ comfrel@online.com.kh & »»»គេហទំព័រ ៖ www.comfrel.org

# ការបោះឆ្នោតជ្រើសរើសសភាជាន់ទាប នៅប្រទេសអាហ្វហ្គានីស្ថាន

កាលពីថ្ងៃទី **១៨ ខែកញ្ញា ឆ្នាំ ២០១០** នៅប្រទេសអាហ្វហ្គានីស្ថាន មាន ការបោះឆ្នោតជ្រើសរើសសភាជាន់ទាប (**Wolesi Jirga Elections**) លើកទីពីរ បន្ទាប់ពីមានការបោះឆ្នោតដំបូងក្នុងឆ្នាំ ២០០៥ ដែល ជាជំហានសំខាន់ដើម្បីពង្រឹងប្រជាធិបតេយ្យនៅក្នុងប្រទេស ហើយក៏ជាជំហានមួយឆ្ពោះទៅរកការបង្រួបបង្រួមប្រជាធិបតេយ្យ ក្នុងចំណោមអ្នកដែលពាក់ព័ន្ធផ្សេងគ្នានៅក្នុងប្រទេស។ ថ្វីបើមាន អំពើហិង្សា ការលួចបន្លំ ភាពមិនប្រក្រតី នៅលើការគូសសន្លឹកឆ្នោត និងមានអ្នកបោះឆ្នោតជាង 3, 6 លាន នាក់ (នៃ 9.2 លានអ្នកមានសិទ្ធិបោះឆ្នោត) បានទៅបោះឆ្នោត វាត្រូវបានកត់សម្គាល់ថា ដំណើរការបោះឆ្នោតបានក្លាយជាកត្តាសំខាន់មួយ នៅក្នុងអន្តរកាលនៃប្រទេសប្រជាធិបតេយ្យមួយនេះ។

## សន្លឹកឆ្នោតជ្រើសរើសសភាជាន់ទាប

សន្លឹកឆ្នោត ត្រូវបានតម្រៀបឈ្មោះ រូបសញ្ញាសម្គាល់ និងរូបថត បេក្ខជនឆ្នាំ ២០១០ ហើយត្រូវបានរចនាឡើងខុសៗគ្នាទៅតាមមណ្ឌលដល់ទៅ ៣៥ ប្រភេទ ដោយក្នុងនោះសម្រាប់ ៣៤ ខេត្ត និងមួយ សម្រាប់ មណ្ឌលជនជាតិភាគតិច គូជី។

## បេក្ខជនចូលរួមប្រជែងការបោះឆ្នោតឆ្នាំ ២០១០

បេក្ខជនសរុប ២ ៥៥៦ នាក់ បានចុះឈ្មោះនៅក្នុងបញ្ជីឈ្មោះបេក្ខជន និងនៅលើសន្លឹកឆ្នោត ដោយរាប់បញ្ចូលទាំងបេក្ខនារី ៤០៦ នាក់ និង បេក្ខជន ជនជាតិភាគតិច គូជី ចំនួន ៥២ នាក់ (១០ នាក់ ជាបេក្ខនារី) ។ មានបេក្ខជនមួយចំនួនត្រូវបានដកចេញពីបញ្ជីដោយសារការបដិសេធន៍ ពីគណៈកម្មាធិការ។ ដើម្បីក្លាយជាបេក្ខជនក្នុងបញ្ជីបោះឆ្នោត បេក្ខភាពនីមួយៗត្រូវបំពេញពាក្យស្នើសុំ ដែលតម្រូវឲ្យ បេក្ខភាព មានសញ្ជាតិជាពលរដ្ឋអាហ្វហ្គានីស្ថាន មិនធ្លាប់ជាប់ទោសពីបទ



ការបោះឆ្នោតនៅអាហ្វហ្គានីស្ថាន

ឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឬបទឧក្រិដ្ឋនានា ឬត្រូវបានគេដកហូតសិទ្ធិពលរដ្ឋដោយតុលាការ យ៉ាងហោចណាស់មានអាយុ ២៥ ឆ្នាំ គិតត្រឹមថ្ងៃជាបេក្ខភាព បានចុះឈ្មោះបោះឆ្នោត ក្នុងបញ្ជី បេក្ខភាពដែលកំពុងកាន់កាប់មុខងារជា មន្ត្រី អ្នករាជការ ឬបុគ្គលិក គណៈកម្មាធិការបោះឆ្នោតឯករាជ្យ ត្រូវតែលាលែងពីមុខតំណែង ហើយចុងក្រោយតម្រូវឲ្យមានអ្នកបោះឆ្នោតយ៉ាងតិច ១ ០០០ នាក់គាំទ្រ និងកក់ប្រាក់ចំនួន ៣០ ០០០ អាហ្វានី (ប្រហែល ៦៤០ ដុល្លាសហរដ្ឋ)។

## ស្ថានីយ៍ និងការិយាល័យបោះឆ្នោត

ស្ថានីយ៍បោះឆ្នោតនីមួយៗ គឺបែងចែកសន្លឹកឆ្នោត




ស្ថានីយបោះឆ្នោត

ត្រឹមតែ ៦០០ សន្លឹកប៉ុណ្ណោះ ក្នុងករណីដែលចំនួន អ្នកបោះឆ្នោតច្រើនលើសពី ៦០០ នាក់ និងត្រូវការសន្លឹកឆ្នោតច្រើនជាងនេះ មន្ត្រីបោះឆ្នោតខេត្ត អាចនឹងពង្រាយស្ថានីយបោះឆ្នោតយថាភាពមួយ ដើម្បីធានាថា សម្ភារៈមិនបានបែងចែករវាងស្ថានីយបោះឆ្នោតដែលនឹងធ្វើឲ្យគណៈកម្មាធិការបោះឆ្នោតមានភាពងាយស្រួលក្នុងការកំណត់ការលួចបន្លំ និងភាពមិនត្រឹមត្រូវ នៅក្នុងមណ្ឌលបោះឆ្នោត។ ៥ ៩០០ មណ្ឌលបោះឆ្នោត និង ១៩ ០០០ ស្ថានីយបោះឆ្នោត នៅក្នុងប្រទេសអាហ្វានីស្ថាន ត្រូវបាន បង្កើតនៅតាមសាលារៀន វិហារអ៊ីស្លាម អគារសាធារណៈ និងពេលខ្លះប្រើតង់ ជាមណ្ឌលបោះឆ្នោត នៅទូទាំងប្រទេស។

## ភាពមិនប្រក្រតីដែលបានកើតឡើងក្នុងពេលបោះឆ្នោតឆ្នាំ ២០១០ ៖

ការគំរាមកំហែង អំពីហិង្សា និងអំណាចទឹកប្រាក់ មានទទួលស្គាល់ថា ជាយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពមួយ ដើម្បីឈ្នះការបោះឆ្នោត ហើយបានប្រានបេក្ខជនជាច្រើនឲ្យឃ្លាតឆ្ងាយពីការបោះឆ្នោតដោយសេរី។ ស្ត្រី និងក្រុមជនជាតិ បានក្លាយជាជនរងគ្រោះ នៅពេលអនុវត្តជាក់ស្តែង ហើយក្រុមដែលងាយរងគ្រោះដទៃទៀត មានផលប៉ះពាល់ដោយការបំភិតបំភ័យពីគណបក្សនយោបាយ ឬបេក្ខជនដែលប្រកួតប្រជែងក្នុងដំណើរការបោះឆ្នោត។ មិនមានរបាយការណ៍នៃបណ្តឹងច្រើនឡើយ ពិសេសទស្សនៈរបស់បេក្ខជនស្ត្រី ដែលមិនត្រូវបានដោះស្រាយ និងបណ្តឹងរបស់ពួកគេ។ ការប្រើប្រាស់រូបភាពឃោសនា មិនមានតុល្យភាពទេ។



រាប់ស្លឹកឆ្នោតក្រោមពន្លឺចង្កៀង

## អនុសាសន៍របស់ មូលនិធិ អាន់ហ្វ្រែល (បណ្តាញការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅអាស៊ី) ៖

- **ការបោះឆ្នោតដែលពាក់ពន្ធ័នឹងបទឧក្រិដ្ឋ និងបណ្តឹងទាក់ទងនឹងការលួចបន្លំ ៖** គណៈកម្មាធិការបោះឆ្នោតឯករាជ្យគួរតែដឹកនាំការអង្កេតដោយមិនលម្អៀងជាបន្ទាន់ ហើយដាក់ទោសអ្នកដែលប្រព្រឹត្តិល្មើស ដោយមិនអាចលើកលែងបាន។
- **ការវាយតម្លៃទូទៅ សម្រាប់ការបំពេញការងាររបស់គណៈកម្មាធិការបោះឆ្នោតឯករាជ្យ** ៖ គណៈកម្មាធិការបោះឆ្នោតឯករាជ្យ គួរតែធ្វើការវាយតម្លៃទូទៅចំពោះប្បញ្ញត្តិរបស់ខ្លួន និងដាក់ទណ្ឌកម្មយ៉ាងតឹងរឹងប្រឆាំង នឹងការលួចបន្លំការបោះឆ្នោត។
- **កំណែទម្រង់ប្រពន្ធ័នៃការចុះឈ្មោះអ្នកបោះឆ្នោត** ៖ ដោយសារមានការពាក់ពន្ធ័ជាមួយនឹង ទិន្នន័យ បច្ចេកទេស ដែលអាចការពារការចុះឈ្មោះច្រើនដង ការបង្ហាញបញ្ជីអ្នកបោះឆ្នោតដោយជាក់លាក់ នៅក្នុង មណ្ឌលបោះឆ្នោតនីមួយៗ គឺសំខាន់ផងដែរ ដើម្បីការពារការបោះឆ្នោតច្រើនដង។ កំណែទម្រង់ដែលគួរឲ្យ សរសើរ គឺការសម្របសម្រួលអ្នកទោសដែលរស់នៅក្នុងពន្ធនាគារ ដើម្បីចៀសវាងការបាត់បង់សិទ្ធិបោះឆ្នោត។
- **ស្ថានីយ៍បោះឆ្នោតស្ត្រី** ៖ ត្រូវការបង្កើនចំនួនស្ថានីយ៍នៅតាមតំបន់ជាច្រើនទៀត សម្រាប់ការបោះឆ្នោតនាពេលអនាគត និងស្ថានីយរបស់ជនជាតិភាគតិច (គូជី) ដែលត្រូវតែតាមដានយ៉ាងយកចិត្តទុកដាក់ ដើម្បីឲ្យមានការកើនឡើងនូវជំនឿចិត្តសម្រាប់អ្នកបោះឆ្នោតអាចបោះឆ្នោតបានដោយសេរី។ មន្ត្រីបោះឆ្នោត ត្រូវតែមានការបណ្តុះបណ្តាលឲ្យបានជាក់លាក់លើដំណើរការ និងដំណោះស្រាយជាមួយនឹងអ្នកអង្កេតការណ៍ និងប្រពន្ធ័ផ្សព្វផ្សាយ។ តួនាទីនៃអ្នកអង្កេតការណ៍ មកពីគណៈកម្មាធិការបោះឆ្នោតឯករាជ្យ ត្រូវតែមានភាពសំខាន់នៅក្នុងពេលប្រតិបត្តិ។
- **ការរាប់សន្លឹកឆ្នោត** ៖ ប្រពន្ធ័ និងនីតិវិធី ត្រូវតែធ្វើឲ្យប្រសើរដើម្បីឲ្យមានការរៀបជាតារាង អំឡុងពេលរាប់សន្លឹកឆ្នោតនៅក្នុងមណ្ឌលបោះឆ្នោត។
- **ការជ្រើសរើសគណៈកម្មាធិការបោះឆ្នោត និងថ្នាក់ក្រោម៖** ដំណើរការជ្រើសរើស នៃសមាជិកគណៈ កម្មាធិការបោះឆ្នោតត្រូវតែ ធ្វើឡើងតាមដំណើរការជ្រើសរើសដ៏សមរម្យមួយដែលគួរតែមានការណែនាំនូវ ដំណើរការតម្លាភាពឲ្យកាន់តែច្រើនជាងនេះ។ សមាជិកនៃ រដ្ឋសភា គួរតែពាក់ពន្ធ័នៅក្នុងដំណើរការនេះផងដែរ។ ការជ្រើសរើសថ្នាក់ក្រោម គួរតែធ្វើឡើងដោយសាធារណៈ ឬធ្វើឲ្យមានការដឹងឮនៅគ្រប់ដំណើរការ។

## បញ្ហាសំខាន់ ដែលពាក់ពន្ធ័នឹងការធ្វើកំណែទម្រង់មាន ៖

- វាសំខាន់ដើម្បីឲ្យមានមូលនិធិបរទេស **នៅក្នុងការដឹកនាំការស្ទង់មតិ និងជំរឿន** សម្រាប់ឲ្យដឹងចំនួនពលរដ្ឋអាហ្វហ្គានីស្ថាន និងចេញអត្តសញ្ញាណបណ្ណ័ដ៏សមរម្យនៅទូទាំងប្រទេស។ អត្តសញ្ញាណ នឹងត្រូវបាន ប្រើប្រាស់ជាឯកសារផ្លូវការ សម្រាប់ប្រើប្រាស់ជាផ្លូវការ និងឯកជន សម្រាប់គ្រប់ការរៀបចំ រាប់បញ្ចូលទាំង ការបោះឆ្នោត។ ការចុះឈ្មោះអ្នកបោះឆ្នោត គួរតែបន្តដំណើរការ និងបញ្ចូលទៅក្នុងកុំព្យូទ័រ សម្រាប់ពលរដ្ឋ អាហ្វានីស្ថាន ទាំងក្នុង និងក្រៅប្រទេស។ សវនកម្ម ការចុះឈ្មោះអ្នកបោះឆ្នោត អាចនឹងធ្វើនៅក្នុងខេត្តនីមួយ ។
- **ច្បាប់ហិរញ្ញវត្ថុពេលឃោសនា គឺជាបញ្ហាដ៏ធំមួយ** ៖ ដើម្បីកំណត់ទីលានប្រកួតប្រជែងដោយយុត្តិធម៌ សម្រាប់បេក្ខជន។ កំណែទម្រង់មួយ គួរតែកំណត់ការចំណាយ ដែលត្រូវការអង្កេត និងដាក់ទណ្ឌកម្ម។ វាអាច នឹងប្រសើរដើម្បីរាប់បញ្ចូល ការដាក់ទណ្ឌកម្មដោយពេញលេញ ចំពោះការប្រើប្រាស់ធនធានរដ្ឋាភិបាលដោយខុសច្បាប់។




ការផ្សាយរបស់គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌

ករណីសិក្សា

# ហិរញ្ញវត្ថុគណបក្សនយោបាយ នៅប្រទេសបារាំង

## ហិរញ្ញវត្ថុក្នុងជីវភាពនយោបាយ

### សេចក្តីផ្តើម

បារាំងជាប្រទេសប្រជាធិបតេយ្យដ៏ចំណាស់មួយនៅអឺរ៉ុប។ ការកសាងនីតិរដ្ឋនៅសាធារណ រដ្ឋមួយនេះ ក៏បានចាប់ផ្តើមតាំងពីជាងពីរសតវត្សមុនមកម្ល៉េះ។ ជាការពិតណាស់ ការបោះឆ្នោតគឺជាប្រធានបទដ៏សំខាន់មួយនៅគ្រប់សង្គមប្រជាធិបតេយ្យ។ ជាពិសេស គឺនៅដំណាក់កាលមុនការបោះឆ្នោត ដែលបេក្ខជនជាគូប្រជែងនយោបាយទាំងអស់ត្រូវខិតខំប្រឹងប្រែងធ្វើយ៉ាងណា ដើម្បីឲ្យខ្លួន អាចទទួលជោគជ័យលើការបោះឆ្នោត។ ការឃោសនាបោះឆ្នោត ក៏បានក្លាយជាកត្តាកំណត់លទ្ធផលបោះឆ្នោតដ៏សំខាន់មួយ។ ជាក់ស្តែងនៅរាល់ការបោះឆ្នោតម្តងៗ បញ្ហានៅក្នុងពេលឃោសនាបោះឆ្នោតតែងតែកើតមានឡើង។ នេះក៏បានបង្ហាញពីឥទ្ធិពលនៃអំណាចសេដ្ឋកិច្ចមកលើនយោបាយផងដែរ។ ហេតុដូច្នេះហើយទើបនីតិវិធីមានរបស់បារាំងត្រូវធ្វើការវិវឌ្ឍន៍ខ្លួន។ ការចាប់ផ្តើមដំបូង គឺនៅឆ្នាំ១៩៨៨ ១៩៩០ ១៩៩៣ ១៩៩៥ និង២០០៣ ដែលសភាជាតិបានអនុម័តច្បាប់ ស្តីពីហិរញ្ញវត្ថុនយោបាយ។ ការវិវឌ្ឍន៍កើតមានជាបន្តបន្ទាប់ដែលពាក់ព័ន្ធដល់ការបង្កើតវិធានថ្មីសំរាប់គ្រប់គ្រងការចំណាយកំឡុងពេលឃោសនាការត្រួតពិនិត្យហិរញ្ញប្បទានជាដើមបេក្ខជនជាដើម។



## ខ្លឹមសារសំខាន់ៗ នៃការបង្កើតក្របខ័ណ្ឌគតិយុត្ត សម្រាប់គ្រប់គ្រងហិរញ្ញវត្ថុនយោបាយ

ការបង្កើតក្របខ័ណ្ឌគតិយុត្ត សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុនយោបាយ ឈរលើគោលការណ៍សំខាន់មួយចំនួនដូចជា៖

- ការទទួលស្គាល់លក្ខន្តិកៈគតិយុត្តរបស់គណបក្សនយោបាយពីសំណាក់រដ្ឋធម្មនុញ្ញ ដើម្បីអនុញ្ញាតឲ្យក្រុមនយោបាយប្រភេទនេះ អាចទទួលបាននូវហិរញ្ញប្បទានសាធារណៈ។
- ការធានាបាននូវតម្លាភាពក្នុងហិរញ្ញវត្ថុរបស់គណបក្សនយោបាយ ក៏ដូចជារបស់បេក្ខជនដែល អាចចៀសវាងបាននូវហិរញ្ញប្បទានទុច្ចរិត និងឥទ្ធិពលអាក្រក់របស់ពួកអ្នកមានអំណាចសេដ្ឋកិច្ចមក លើអ្នកនយោបាយ។ ដូច្នេះហើយ ទើបចាប់ពីឆ្នាំ១៩៩៥មក ហិរញ្ញប្បទានពីនីតិបុគ្គលពោលគឺបណ្តាសហគ្រាស ក្រុមហ៊ុនទាំងឡាយត្រូវបានហាមឃាត់។
- ការកម្រិតការចំណាយទៅលើការឃោសនាបោះឆ្នោត ដោយគោរពនូវគោលការណ៍សមភាពរវាងបេក្ខជនឈរឈ្មោះទាំងអស់ដោយមិនប្រកាន់ពីភាពខុសគ្នានៃធនធាន។
- ការរៀបចំនូវហិរញ្ញប្បទានសាធារណៈ ដើម្បីតបស្នងនឹងការហាមឃាត់ហិរញ្ញប្បទានពីសំណាក់ពួកសហគ្រាស។
- ការបង្កើតទណ្ឌកម្មធ្ងន់ធ្ងរ ទៅលើអ្នកដែលប្រព្រឹត្តបទល្មើសបន្លំសន្លឹកឆ្នោត ដែលអាចឈានទៅដល់ការដកហូតសិទ្ធិឈរឈ្មោះបោះឆ្នោតបណ្តោះអាសន្ន។



*ប្រធានាធិបតីបារាំង ហ្សាគុស៊ី*

- ការគ្រប់គ្រងហិរញ្ញវត្ថុការឃោសនាដោយអាជ្ញាធររដ្ឋបាលឯករាជ្យមួយ។ គួរបញ្ជាក់ផងដែរថា ការងាររៀបចំការបោះឆ្នោតនៅប្រទេសបារាំង គឺត្រូវបានរៀបចំឡើងដោយក្រសួងមហាផ្ទៃ និងអាជ្ញាធរដែនដី។
- ការប្រកាសទ្រព្យសម្បត្តិរបស់មន្ត្រីជាប់ឆ្នោតទាំងអស់ ក្នុងទិសដៅធ្វើយ៉ាងណាធានាបានថាអ្នកទាំងនោះពុំបានឆ្លៀតឱកាសពីការទទួលបានតំណែងទាំងនេះដើម្បីធ្វើការមានបានតាមរយៈអំពើពុករលួយនានាឡើយ។
- តាមរយៈការដាក់ចេញនូវវិធានគ្រប់គ្រងហិរញ្ញវត្ថុ និងហិរញ្ញប្បទានសាធារណៈនេះ ច្បាប់ក៏ បានបង្កើតនូវគោលការណ៍សមភាពរវាងបុរស និងស្ត្រីក្នុងការចូលរួមក្នុងវិស័យនយោបាយផងដែរ។

ក្នុងន័យនេះ តាមរយៈហិរញ្ញប្បទានសាធារណៈ គណបក្សនយោបាយណា ដែលមិនបានគោរព គោលការណ៍ខាងលើ នឹងមិនត្រូវបានទទួលហិរញ្ញប្បទានពីរដ្ឋបានឡើយ។

## ហិរញ្ញប្បទានសាធារណៈ

ហិរញ្ញប្បទានសាធារណៈ គឺជាការផ្តល់ជូនពីរដ្ឋនូវថវិកាសំរាប់ទ្រទ្រង់ការចំណាយផ្សេងៗរបស់គណបក្សនយោបាយ។ ហិរញ្ញប្បទាននេះ ត្រូវគណនាផ្អែកទៅតាមលទ្ធផលបោះឆ្នោតកន្លងទៅ។ ថវិកាដែលត្រូវផ្តល់ឲ្យត្រូវបែងចែកក្រោមពីភាគ។ ភាគទីមួយត្រូវធ្វើការបែងចែកដល់គណបក្សនយោបាយណា ដែលមានបេក្ខជនឈរឈ្មោះក្នុងយ៉ាងតិច៥០មណ្ឌល ហើយដែលមានសំលេងគាំទ្រលើសពី១%នៃសំលេងឆ្នោតដែលបានបោះ។ ចំណែកឯភាគទីពីរត្រូវបានបម្រុងទុកសំរាប់គណបក្សដែលមានអាសនៈនៅរដ្ឋសភា។




ហិរញ្ញប្បទានសាធារណៈមួយប្រភេទទៀត គឺសំរាប់ផ្តល់ដល់បេក្ខជនដែលបានចូលរួមក្នុងការបោះឆ្នោត។ ហិរញ្ញប្បទាននេះ ធ្វើឡើងក្រោមរូបភាពជាសំណងដល់ការចាយវាយកាលពីពេលឃោសនាបោះឆ្នោត។ ក៏ប៉ុន្តែមិនមែនគ្រប់បេក្ខជនដែលបានឈរឈ្មោះទាំងអស់នឹងទទួលបាននូវហិរញ្ញប្បទានទាំងនេះទេ។ បេក្ខជនដែលមានសំលេងគាំទ្រលើសពី៥% នៃសម្លេងឆ្នោតបានបោះទើបអាចទទួលបានការសងពីរដ្ឋមកវិញ។ ម្យ៉ាងទៀត បេក្ខជនក៏ត្រូវគោរពតាមកាតព្វកិច្ចគណនីមួយចំនួន ដើម្បីអាចទទួលបានសំណងមកវិញដែរ។




ទោះជាយ៉ាងណាក្តី ការសងនេះពុំមានលក្ខណៈពេញលេញនោះទេ។ ទឹកប្រាក់ដែលត្រូវសងពីរដ្ឋមិនអាចលើសពី៥០%នៃការកម្រិតសំរាប់ការចំណាយឡើយ ហើយក៏មិនត្រូវលើសពីចំណាយជាក់ស្តែងរបស់បេក្ខជនដែរ។ បានសេចក្តីថា បេក្ខជនដែលបានចំណាយតិចជាងពាក់កណ្តាលនៃការកម្រិតសំរាប់ការចំណាយដោយច្បាប់ ទើបអាចទទួលបានសំណងទាំងស្រុងពីរដ្ឋ ហើយពុំមានករណីផ្សេងពីនេះឡើយ។

## បទប្បញ្ញត្តិសម្រាប់ហិរញ្ញប្បទានឯកជន

ជាទូទៅ ហិរញ្ញប្បទានសាធារណៈ ពិតជាមិនអាចគ្រប់គ្រាន់សំរាប់ទ្រទ្រង់ចំណាយរបស់ គណបក្សនយោបាយ ឬបេក្ខជននៅពេលឃោសនារកសំលេងឆ្នោតបានឡើយ។ ដូច្នេះហិរញ្ញប្បទានឯក ជនគឺមានចាំបាច់ដដែល។

ចាប់តាំងពីឆ្នាំ១៩៩៥ មកច្បាប់បានកាតផ្តាច់ទាំងស្រុងនូវហិរញ្ញប្បទាន ដែលបានមកពីនីតិ បុគ្គល ពោលគឺពពួកក្រុមហ៊ុន និងសហគ្រាសទាំងឡាយ។

ថ្វីត្បិតតែ រូបវន្តបុគ្គលមិនត្រូវបានហាមឃាត់ពីការធ្វើហិរញ្ញប្បទានយ៉ាងណាក្តី ក៏ការធ្វើអំ ណោយទៅដល់គណបក្សនយោបាយ ឬបេក្ខជនត្រូវតែស្ថិតក្រោមវិធានមួយដ៏តឹងរឹងផងដែរ។ បទដ្ឋានទាំងនោះមាន ដូចជាការកម្រិតនូវតំលៃនៃអំណោយ (មិនឲ្យលើសពី៤៦០០€សំរាប់បុគ្គលម្នាក់ក្នុងមួយឆ្នាំ) ការតម្រូវឲ្យប្រតិបត្តិមធ្យោបាយមូលប្បទានប័ត្រ (ចំពោះអំណោយដែលមានចំនួនលើសពី១៥០€) កាតព្វកិច្ចត្រូវធ្វើបង្កាន់ដៃសំរាប់ការត្រួតពិនិត្យ ព្រមទាំងការយកពន្ធពីការធ្វើអំណោយផងដែរ។




## កម្រិតការចំណាយសំរាប់ការឃោសនា

ដើម្បីធានានូវសមភាពរវាងបេក្ខជនប្រកួតប្រជែងក្នុងការបោះឆ្នោត ការកម្រិតការចំណាយមួយត្រូវបានដាក់ចេញ។ ការកម្រិតនេះត្រូវធ្វើដោយគិតគូរអំពីចំនួនប្រជាជនក្នុងមណ្ឌល ក៏ដូចជាតំលៃសំភារៈទូទៅផងដែរ។ ដូច្នេះឃើញថា ការកម្រិតនេះមានលក្ខណៈបត់បែនបានទៅតាមកត្តាទាំងអស់នេះផងដែរ។

ដើម្បីរកឲ្យឃើញថា ការចំណាយសំរាប់ការឃោសនាមួយត្រូវកម្រិតត្រឹមណា គេត្រូវយកទឹកប្រាក់៣៨០០€បូកនឹងផលគុណនៃចំនួនប្រជាជនសរុបក្នុងមណ្ឌលនឹង០,១៥€។ ចំនួនដែលរកឃើញនេះ នឹងត្រូវយកទៅគុណនឹងមេគុណមួយ។ រូបមន្តដែលត្រូវយកមកគណនាត្រូវបានកំណត់ដោយច្បាប់។ ក៏ប៉ុន្តែមេគុណដែលត្រូវយកគុណបន្ថែមនឹងចំនួនរកឃើញ អាចមានការប្រែប្រួល។ការប្រែប្រួលនេះគឺត្រូវធ្វើឡើងដោយបទបញ្ជានៃអំណាចនីតិប្រតិបត្តិ។ ជាឧទាហរណ៍ មេគុណនេះបានប្រែប្រួលពី ១,១២មកដល់១,២៦ហើយនៅឆ្នាំ២០០៨ (តាមរយៈក្រិត្យលេខ ២០០៨-១៣០០)




## ការគ្រប់គ្រងហិរញ្ញវត្ថុសំរាប់ការឃោសនា

រាល់ចំណូល និងចំណាយសំរាប់ការឃោសនាបោះឆ្នោត ត្រូវប្រមូលផ្តុំក្នុងគណនីទោលមួយ។បេក្ខជនមិនមានសិទ្ធិ ក្នុងការចាត់ចែងគណនីសំរាប់ការឃោសនារបស់ខ្លួនបានឡើយ។ បេក្ខជនឈរឈ្មោះមានកាតព្វកិច្ច ត្រូវតែងតាំងតំណាងហេរញ្ញិកមួយសំរាប់គ្រប់គ្រងគណនីរបស់ខ្លួន។តំណាងហិរញ្ញិកនេះអាចជារូបវន្តបុគ្គលដែលមានសមត្ថភាព ឬជាសមាគមហិរញ្ញវត្ថុនយោបាយ។




ការគ្រប់គ្រងហិរញ្ញវត្ថុសំរាប់ការឃោសនា ត្រូវធានាដោយអាជ្ញាធររដ្ឋបាលឯករាជ្យមួយ។គណៈកម្មការជាតិគណនីបោះឆ្នោត និងហិរញ្ញវត្ថុនយោបាយ ត្រូវបានបង្កើតឡើងសំរាប់ត្រួតពិនិត្យគណនីរបស់បេក្ខជនកំឡុងពេលឃោសនាបោះឆ្នោត។ ស្ថាប័ននេះមានសិទ្ធិ និងអំណាចក្នុងការត្រួតពិនិត្យគណនីរបស់បេក្ខជន អាចទទួលយកបញ្ជូនត្រឡប់ទៅវិញដើម្បីកែសម្រួល ឬច្រានចោលតែម្តង។ គណនីណាដែលត្រូវបានច្រានចោល គឺមិនអាចទទួលបានសំណងពីរដ្ឋវិញបានឡើយ។ ប្រសិនបើរកឃើញភាពមិនប្រក្រតី គណៈកម្មការនេះមានសិទ្ធិប្តឹងទៅស្ថាប័នអយ្យការចំពោះរឿងព្រហ្មទណ្ឌ។ ក្រុមប្រឹក្សាធម្មនុញ្ញ ក៏មានភារៈទទួលពាក្យបណ្តឹងពីគណៈកម្មាធិការជាតិគណនីបោះឆ្នោត និងហិរញ្ញវត្ថុនយោបាយផងដែរ។ តាមរយៈនីតិវិធីនេះ ចៅក្រមធម្មនុញ្ញអាចប្រកាសដកហូតសិទ្ធិឈរឈ្មោះបោះឆ្នោតពីបេក្ខជនជាប់ចោទផងដែរ។








# ឃ្លាំមើល សភា និង តំណាងរាស្ត្រ

នៅក្នុងរបាយការណ៍ឃ្លាំមើលសភា និងតំណាងរាស្ត្រ ពីខែកក្កដា ដល់ខែកញ្ញា ២០១០នេះ ខុមហ្វ្រែលនឹងបង្ហាញការរកឃើញ និងការសង្កេតរបស់ខ្លួនទាក់ទងនឹងការបន្តមានអតុល្យភាពនៃអំណាចនីតិបញ្ញត្តិចំពោះអំណាចនីតិប្រតិបត្តិ ពិសេសការបន្តធ្លាក់ទន់ខ្សោយនៃអំណាចស្ថាប័ននីតិបញ្ញត្តិ និងការបំពេញតួនាទីរបស់អ្នកតំណាងរាស្ត្រនៅក្នុងវិមានរដ្ឋសភា។

អតុល្យភាពអំណាចនីតិបញ្ញត្តិក្នុងនីតិកាលទី៤នេះ ចំពោះអំណាចនីតិប្រតិបត្តិបន្តមានកាន់តែខ្លាំង នៅពេលដែលថ្នាក់ដឹកនាំនៃអំណាចទាំងពីរមកពីគណបក្សតែមួយ។

ការបំពេញតួនាទីរបស់អ្នកតំណាងរាស្ត្រ ដែលមិនមកពីគណបក្សកាន់អំណាចក៏កាន់តែពិបាកក្នុងការឃ្លាំមើលការងាររបស់រាជរដ្ឋាភិបាល។

ក្រុមអ្នកតំណាងរាស្ត្រមកពីគណបក្សសមរង្ស៊ី ដែលជាគណបក្សប្រឆាំងបានបង្ហាញការលំបាករបស់ខ្លួននៅក្នុងសន្និសីទសារព័ត៌មាននៅខែសីហា ឆ្នាំ២០១០ ថា អ្នកតំណាងរាស្ត្ររបស់ខ្លួនបានដាក់លិខិតទៅរាជរដ្ឋាភិបាលចំនួន ៤៧ច្បាប់ ចាប់ពីខែមករារហូតដល់ខែសីហា ២០១០ ដែលលិខិតនោះរួមមានការអន្តរាគមន៍ អំពាវនាវ ដាក់សំនួរ ស្នើឲ្យបំភ្លឺនៅរដ្ឋសភា ក៏ប៉ុន្តែមានការឆ្លើយមកវិញតែ ១៥ លិខិតប៉ុណ្ណោះ។

តាមទិន្នន័យខុមហ្វ្រែលទទួលបាន ក្នុងរយៈពេល៣ខែ (កក្កដា ដល់ កញ្ញា) មានលិខិតអ្នកតំណាងរាស្ត្រចំនួន១២ច្បាប់ រួមមានការអន្តរាគមន៍ ដាក់សំណួរដល់រាជរដ្ឋាភិបាល ការឆ្លើយបំភ្លឺនៅរដ្ឋសភា។ ទោះបីយ៉ាងណា ត្រឹមចុងខែ កញ្ញា ខុមហ្វ្រែល មិនមានព័ត៌មានទាក់ទងនឹងការឆ្លើយតបលិខិតទាំងនោះនៅឡើយទេ។

ការសង្កេតកន្លងមកក៏បង្ហាញដែរថា ប្រធានអង្គប្រជុំសភាជារឿយៗតែងតែការពារដល់មន្ត្រីរាជរដ្ឋាភិបាលដែលមកបំភ្លឺនៅរដ្ឋសភា តាមរយៈមិនឲ្យតំណាងរាស្ត្រសួរបន្ថែម ឬសួរដេញដោលទៅលើចម្លើយរបស់មន្ត្រីរាជរដ្ឋាភិបាលដែលមកបំភ្លឺ។

តុល្យភាពអំណាចនៃរដ្ឋសភាចំពោះរាជរដ្ឋាភិបាល នឹងកាន់តែធ្លាក់ចុះថែមទៀត ប្រសិនបើមិនមានការធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុង ដែលការពារ និងធានាដល់តួនាទីរបស់គណបក្សប្រឆាំងឲ្យមានក្នុងរចនាសម្ព័ន្ធថ្នាក់ដឹកនាំនៃស្ថាប័នរដ្ឋសភាទេនោះ។

ការសង្កេតក្នុងរយៈពេលនេះក៏បង្ហាញដែរថា មានចលនាទាំងក្នុងស្ថាប័នសភា និងស្ថាប័នអន្តរជាតិឲ្យមានការយកចិត្តទុកដាក់ពីលទ្ធភាពបង្កើតក្រុមស្ត្រីតំណាងរាស្ត្រដើម្បីដោះស្រាយបញ្ហាស្ត្រី ទោះបីយ៉ាងណាការសង្កេតបង្ហាញថា វាហាក់មានការលំបាកសម្រាប់ការធ្វើការរួមគ្នារវាងស្ត្រីតំណាងរាស្ត្ររវាងគណបក្សកាន់អំណាច និងគណបក្សប្រឆាំង ជាពិសេសបន្ទាប់ពីមានការប្តឹងប្តល់ទៅវិញទៅមករវាងថ្នាក់ដឹកនាំគណបក្សទាំងពីរ។

ក្នុងរយៈពេលរដ្ឋសភាសម្រាកមិនប្រជុំ អ្នកតំណាងរាស្ត្រភាគច្រើនបានចុះមូលដ្ឋានជួបប្រជាពលរដ្ឋ ជួបសមាជិកគណបក្ស និងអាជ្ញាធរជាដើម។

ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រនៅក្នុងរយៈពេល ៣ខែ (កក្កដា ដល់ កញ្ញា ២០១០) តាមព័ត៌មានខុមហ្វ្រែល ទទួលបានបង្ហាញថា មានអ្នកតំណាងរាស្ត្រប្រមាណ៨១រូប (ប្រមាណ ៦៦% នៃអ្នកតំណាងរាស្ត្រសរុប ១២៣រូប) បានចុះមូលដ្ឋានសរុបបានប្រមាណ៣៨៦លើក។ ចំនួននេះបើប្រៀបធៀបទៅនឹងរយៈពេល ៣ ខែមុនគឺពីខែ មេសា ដល់ ខែមិថុនា ដែលជារយៈពេលសម័យប្រជុំលើកទី ៤ គឺមានចំនួនប្រហាក់ប្រហែលគ្នា (មានរហូតដល់ ៣៩៦លើក ហើយមានអ្នកតំណាងរាស្ត្រតែ ៧៣រូប)។

ក្នុងចំណោមតំណាងរាស្ត្រទាំង៨១រូប ដែលបានចុះមូលដ្ឋាន មានតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាសរុប៥៨រូប(ស្មើនឹង៦៤% នៃតំណាងរាស្ត្រគណបក្សនេះសរុប៩០រូប)។ តំណាងរាស្ត្រគណបក្សសមរង្ស៊ីសរុប១៨រូប (ស្មើនឹង៦៩%នៃតំណាងរាស្ត្រគណបក្សនេះសរុប ២៦រូប)។ ចំណែកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សដែលមានចំនួន៣នាក់បានចុះមូលដ្ឋានទាំងអស់។ តំណាងរាស្ត្រគណបក្សហ្វ៊ុនស៊ិនប៉ិច និងតំណាងរាស្ត្រគណបក្សជាតិនិយម (អតីតនរោត្តមរណឫទ្ធិ)

១រូប ក្នុងចំណោម ២រូបដូចគ្នា បានចុះមូលដ្ឋាន ។

តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាទាំង ៥៨រូប បានចុះមូលដ្ឋានសរុប ២៦១លើក ឬជាមធ្យមអ្នកតំណាងរាស្ត្រម្នាក់បានចុះមូលដ្ឋានសរុប៥លើកក្នុងរយៈពេល ៣ខែនេះ។ តំណាងរាស្ត្រសមរង្ស៊ីទាំង១៨រូបបានចុះមូលដ្ឋានសរុប១០៨លើក ឬជាមធ្យមអ្នកតំណាងរាស្ត្រម្នាក់បានចុះមូលដ្ឋានសរុប៦លើក ក្នុងរយៈពេល ៣ខែនេះ។

ចំណែកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស គណបក្សជាតិនិយម និងគណបក្សហ្វ៊ុនស៊ិនប៉ិចរួមគ្នាចុះមូលដ្ឋានសរុបបានចំនួន ១៧លើក។

<u>ក្រាហ្វិកទី១៖ ភាគរយចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគណបក្សធៀបភាគរយនៃអាសនៈសភាសរុបតាមគណបក្ស</u>




ក្រាហ្វិកទីមួយបង្ហាញថា ចំនួនចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគណបក្ស គឺស្ទើរតែសមាមាត្រទៅនឹងអាសនៈសភាដែលគណបក្សនីមួយៗទទួលបាន។ គណបក្សប្រជាជនកម្ពុជាបានចុះមូលដ្ឋានដែលមានចំនួនច្រើនជាងគេរហូតដល់ ២៦១លើក។ ប៉ុន្តែបើប្រៀបធៀបភាគរយនៃចំនួនអ្នកតំណាងរាស្ត្ររបស់គណបក្សនីមួយៗ ភាគរយនៃចំនួនតំណាងរាស្ត្រគណបក្សសមរង្ស៊ីបានចុះមូលដ្ឋាន គឺខ្ពស់ជាងគេ។ បានន័យថា អ្នកតំណាងរាស្ត្រគណបក្សនេះបានចុះមូលដ្ឋាន ២៨% នៃចំនួនបេសកកម្មទាំងអស់ បើប្រៀបទៅនឹងចំនួនតំណាងរាស្ត្រគណបក្សនេះដែលមានតែ ២១% នៃចំនួនតំណាងរាស្ត្រទាំងអស់។

តំណាងរាស្ត្រគណបក្ស៣ ទៀត គឺគណបក្សសិទ្ធិមនុស្ស គណបក្សជាតិនិយម និងគណបក្សហ្វ៊ុនស៊ិនប៉ិច ក៏បានខិតខំចុះទៅមូលដ្ឋានច្រើនដែរ បើទោះបីចំនួនអ្នកតំណាងរាស្ត្ររបស់ខ្លួនមានតិចក៏ដោយ។

<u>តារាងទី ១៖ គោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគណបក្ស</u>

| គោលបំណងនៃការចុះមូលដ្ឋានទាំង ២៩០លើក របស់តំណាងរាស្ត្រទាំង៧០រូប | គណបក្សនយោបាយ | | | | | សរុបនៃគោលបំណង |
|---|---|---|---|---|---|---|
| | ៥៨ រូប | ១៨ រូប | ៣ រូប | ១ រូប | ១ រូប | |
| សាកសួរសុខទុក្ខ ចែកអំណោយនិងការសម្ពោធសមិទ្ធផលនានា | ១៨៣ (៧០%) | ៣៦ (៣៣%) | ៣ (៣០%) | ០ | ១ (២០%) | ២២3 (៥៨%) |
| ការចុះពង្រឹងផ្ទៃក្នុង និង បណ្តាញគណបក្ស | ៥០ (១៩%) | ៥៦ (៥២%) | ៤ (៤០%) | ២ (១០០%) | ២ (៤០%) | ១១៤ (៣០%) |
| ការចុះអមដំណើរជាក្រុម ឬ អមដំណើរថ្នាក់ដឹកនាំ | ១៧ (៦%) | ០ | ០ | ០ | ០ | ១៧ (៤%) |
| ការចូលរួមក្នុងវេទិកាសាធារណៈ | ៤ (២%) | ១០ (៩%) | ៣ (៣០%) | ០ | ២ (៤០%) | ១៩ (៥%) |
| ការអន្តរាគមន៍ និងដោះស្រាយបញ្ហានានា | ៧ (៣%) | ៦ (៦%) | ០ | ០ | ០ | ១៣ (៣%) |
| សរុបគោលបំណងតាមគណបក្ស | ២៦១ | ១០៨ | ១០ | ២ | ៥ | ៣៨៦(១០០%) |





តារាងទី ១ បានបង្ហាញថា ការចុះមូលដ្ឋានភាគច្រើនរបស់អ្នកតំណាងរាស្ត្រគឺផ្តោតទៅលើការចុះមូលដ្ឋានក្នុងគោលបំណងសាកសួរសុខទុក្ខ ចែកអំណោយ និងការសម្ពោធសមិទ្ធផលនានាដែលសរុបមានរហូតដល់ ២២៣លើក និងការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្ស ១១៤លើក ចំណែកការអន្តរាគមន៍ និងដោះស្រាយបញ្ហានានាមានចំនួនតិចជាងគេគឺ ១៣លើក ស្មើនឹង៣% ។

- **តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា៖** អ្នកតំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជា ផ្តោតទៅលើការសួរសុខទុក្ខ ចែកអំណាយ និងការសម្ពោធសមិទ្ធផលនានា មានភាពច្រើនលើសលប់ដល់ទៅ ១៨៣លើក ស្មើនឹង ៧០% បើប្រៀបធៀបនឹងគោលបំណងនៃការចុះមូលដ្ឋានក្នុងគណបក្សនេះ។ លំដាប់បន្ទាប់គឺការពង្រឹងបណ្តាញគណបក្សដែលមាន ១៩%ស្មើនឹង ៥០លើក។ ការអមដំណើរថ្នាក់ដឹកនាំមានចំនួន ១៧លើក ហើយការចុះជួយអន្តរាគមន៍មានចំនួនតិចតួចក្នុងបក្ស តែលើសគេបើប្រៀបធៀបជាមួយគណបក្សផ្សេងគឺ ៧ដងស្មើនឹង ៣% និងការចូលរួមវេទិកាសាធារណៈមានតិចតួចគឺ ២%ប៉ុណ្ណោះ។

ករណីខ្លះៗនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាមានដូចជា៖ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១០ អ្នកតំណាងរាស្ត្រ ទេស ហ៊ាញ មណ្ឌលបាត់ដំបង បានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខលោកគ្រូ អ្នកគ្រូនៅសាលាបឋមសិក្សាកន្ទឺ២ សរុបចំនួន១១នាក់ និងសំណេះសំណាលសួរសុខទុក្ខក្រុមបច្ចេកទេសដែលកំពុងវាស់ស្ទង់ស្ថាបនាប្រព័ន្ធប្រឡាយស្រោចស្រពនៅឃុំកន្ទឺ២ ស្រុកបាណន់។

ចំណែកការចុះអន្តរាគមន៍វិញគឺ កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១០ អ្នកតំណាងរាស្ត្រ សួស កាណាន មណ្ឌលព្រះសីហនុ បានចុះជួបប្រជាពលរដ្ឋ ហើយបន្ទាប់មកធ្វើអន្តរាគមន៍តាមរយៈលិខិតលេខ ០២៥/១០កតរខសន ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១០ ជូនទៅឯកឧត្តមអភិបាលខេត្តព្រះសីហនុ ដើម្បីជួយដោះស្រាយបញ្ហាពាក្យបណ្តឹងប្រជាពលរដ្ឋចំនួន៩២គ្រួសារ ដែលមានទំនាស់ដីធ្លីនៅភូមិ៤ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ជាមួយលោក ស ស៊ឹង យោធាសីករង ខេត្តព្រះសីហនុ និងក្រុមហ៊ុនចំរើនជាតិដែលកើតមានចាប់តាំងពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៧ រហូតមកដល់បច្ចុប្បន្ននេះ នៅមិនទាន់បានដោះស្រាយ។

- **តំណាងរាស្ត្រគណបក្សសមរង្ស៊ី៖** ចំណែកការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រមកពីគណបក្សសមរង្ស៊ីបានផ្តោតខ្លាំងលើការពង្រឹងបក្ស ដែលមានដល់៥២% (៥៦លើក ប្រៀបធៀបក្នុងបក្ស)។ អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីបាននាំមុខតំណាងរាស្ត្រគណបក្សដទៃទៀតក្នុងការចូលរួមវេទិកាសាធារណៈដែលមាន ១០លើក (ស្មើនឹង ៩%) ហើយការចុះជួយអន្តរាគមន៍មាន ៦លើក ស្មើនឹង៦% ។

ការចុះមូលដ្ឋានខ្លះៗរបស់អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីដូចជា ករណីតំណាងរាស្ត្រមណ្ឌលកំពង់ធំ ម៉ែន សុថាវិរិន្ទ្រ បានចុះតាមស្រុកដើម្បីធ្វើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាបក្សប្រចាំស្រុកទាំង០៨ ក្នុងខេត្តកំពង់ធំ ពីថ្ងៃទី១-២-៣ ខែកញ្ញា ឆ្នាំ២០១០ ។ ចំណែកករណីអន្តរាគមន៍គឺអ្នកតំណាងរាស្ត្រ មួរ សុខហួរ មណ្ឌលកំពតបានចុះមកជួបកម្មកររោងចក្រ អឹម រ៉េ

ដើម្បីជួយ គាំទ្រកម្មករក្នុងការទាមទារដំឡើងប្រាក់ខែគោល ចំនួន១១ដុល្លារ បន្ថែមលើប្រាក់ខែបច្ចុប្បន្ន និងទាមទារអោយមានទឹកស្អាតសំរាប់ប្រើប្រាស់ បរិស្ថានល្អក្នុងអាគាររោងចក្រ កាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១០ ។

- **តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស:** តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សបានផ្តោតលើការពង្រឹងបក្ស ចុះសួរសុខទុក្ខចែកអំណោយ និងចូលរួមជាវាគ្មិននៅវេទិកាសាធារណៈចំនួនប្រហាក់ប្រហែលគ្នាគឺ ៣ លើក ស្មើនឹងជាមធ្យម ៣៥%នៃបេសកកម្មចុះមូលដ្ឋានរបស់គណបក្សខ្លួន។ អ្នកតំណាងរាស្ត្រ យ៉ែម បុញ្ញឫទ្ធិ មណ្ឌលព្រៃវែងបានអញ្ជើញជាអធិបតីក្នុងវេទិកាស្តីពីការបោះឆ្នោត និងលំហប្រជាធិបតេយ្យដែលរៀបចំដោយគណៈកម្មាធិការខុមហ្វ្រែលដែលសមាជិកចូលរួមប្រហែល៨៨នាក់កាលពីថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១០ ។
- **តំណាងរាស្ត្រគណបក្សហ្វ៊ុនស៊ិនប៉ិច:** ក្នុងគណបក្សនេះ មានតែតំណាងរាស្ត្រ ញឹក ប៊ុនឆៃ បានចុះមូលដ្ឋានចំនួន ២លើក ដោយផ្តោតលើការចុះពង្រឹងបណ្តាញបក្ស ដូចជាកាលពីថ្ងៃទី១៨ ខែកក្កដា ២០១០ បានអញ្ជើញចូលរួមប្រជុំជាមួយថ្នាក់ដឹកនាំគណបក្សគណបក្សជាតិនិយមក្នុងគោលបំណងបញ្ចូលសម្ពន្ធ័ភាពគណបក្សទាំង២ ក្នុងនោះមានសមាជិកបក្សចូលរួមប្រហែល ៣៧០នាក់ផងដែរ។
- **តំណាងរាស្ត្រគណបក្សជាតិនិយម:** តំណាងរាស្ត្របានចុះដោយផ្តោតលើកការពង្រឹងបក្ស សួរសុខទុក្ខចែកអំណោយ និងចូលរួមវេទិកា ជាមធ្យម ៣៣% នៃការចុះមូលដ្ឋានរបស់គណបក្សដែលចុះសរុបចំនួន ៥លើក។ ឧទាហរណ៍ អ្នកតំណាងរាស្ត្រ សៅ រ៉ានី មណ្ឌលព្រៃវែង ដូចជាកាលពីថ្ងៃទី១៥ ខែ៧ ២០១០ រួមនឹងអ្នកតំណាងរាស្ត្រ ទាំងអស់ដែលជាសមាជិកគណៈកម្មការទី៤ បានចុះទៅសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ នៅឃុំទួលពង្រ ស្រុកម៉ាឡៃ ហើយបានចែកអំណោយដល់អ្នកចូលរួមក្នុងម្នាក់សារ៉ុង១ ថវិកា១០០០០៛ ព្រមទាំងឧបត្ថម្ភថវិកា ១០ម៉ឺនរៀលដល់រដ្ឋបាលនៅឃុំទួលពង្រ។

តារាងទី ២៖ អ្នកតំណាងរាស្ត្រចែលចុះមូលដ្ឋាន និងអន្តរាគមន៍បានច្រើនជាងគេ៥រូប

| ល.រ | ឈ្មោះ តំណាងរាស្ត្រ | គណបក្ស | គោលបំណង | | | | | សរុប |
|---|---|---|---|---|---|---|---|---|
| | | | អន្តរាគមន៍ | សួរសុខទុក្ខ | ពង្រឹង បក្ស | វេទិកា | អមដំណើរ | |
| ១ | មូរ សុខហួរ | សម រង្ស៊ី | ២ | ១៥ | ១១ | ១ | ០ | ២៩ |
| ២ | ទេស ហ៊ាញ | ប្រជាជនកម្ពុជា | ០ | ១៨ | ០ | ០ | ៤ | ២២ |
| ៣ | កាទើ តូយ៉េប | ប្រជាជនកម្ពុជា | ០ | ១៥ | ២ | ០ | ២ | ១៩ |
| ៤ | លី គឹមលៀង | ប្រជាជនកម្ពុជា | ០ | ១៥ | ០ | ០ | ២ | ១៧ |
| ៤ | ឡោក ខេង | ប្រជាជនកម្ពុជា | ០ | ១០ | ៦ | ០ | ១ | ១៧ |

តារាងទី២នេះបង្ហាញថាអ្នកតំណាងរាស្ត្រស្រីគណបក្សសមរង្ស៊ីមណ្ឌលកំពត មូរ សុខហួរ បាននាំមុខគេក្នុងការចុះមូលដ្ឋានសរុបបាន ២៩លើក តាមពីក្រោយដោយតំណាងរាស្ត្រគណបកស្សប្រជាជនកម្ពុជាមណ្ឌលបាត់ដំបង ទេស ហ៊ាញ ដែលបានចុះមូលដ្ឋានសរុប ២២លើក អ្នកតំណាងរាស្ត្រមណ្ឌលក្រចេះ កាទើ តូយ៉េប ចំនួន១៩លើក អ្នកតំណាងរាស្ត្រមណ្ឌលបាត់ដំបង លី គឹមលៀង និង អ្នកតំណាងរាស្ត្រមណ្ឌលភ្នំពេញ ឡោក ខេង បានចំនួន ១៧ លើកដូចគ្នា។

អ្នកតំណាងរាស្ត្រទាំង៥រូបនេះក៏ផ្តោតការចុះមូលដ្ឋានរបស់ខ្លួនក្នុងការជួបសួរសុខទុក្ខប្រជាពលរដ្ឋ និងចុះពង្រឹងគណបក្សរបស់ខ្លួន ចំណែកការចុះមូលដ្ឋានដើម្បីអន្តរាគមន៍ជួយប្រជាពលរដ្ឋកំពុងមានជម្លោះ និងការចូលរួមក្នុងវេទិកាសិក្ខាសាលាសាធារណៈ គឺមានតែតំណាងរាស្ត្រ មូរ សុខហួរ មួយប៉ុណ្ណោះ។





ករណីសិក្សា

# ហិរញ្ញវត្ថុគណបក្សនយោបាយ នៅប្រទេសប្រទេសឥណ្ឌូនេស៊ី



ចាប់តាំងពីឆ្នាំ១៩៩៩ ប្រទេសឥណ្ឌូនេស៊ីដែលធ្លាប់ជារដ្ឋដែលប្រកាន់យករបបគណបក្សដឹកនាំតែមួយនោះ បានប្រែក្លាយជាប្រទេសប្រជាធិបតេយ្យថ្មីមួយទៀតដែលមានការចូលរួមប្រកួតប្រជែងពីគណបក្សរហូតដល់៤៣គណបក្សនយោបាយ ហើយមាន៤១គណបក្សដែលមានអាសនៈក្នុងសភា។

ដូច្នេះវាមិនមែនជាការភ្ញាក់ផ្អើលទេ ដែលប្រទេសទើបនឹងទទួលយករបបប្រជាធិបតេយ្យនេះប្រឈមនឹងបញ្ហាជាច្រើន ដែលក្នុងនោះហិរញ្ញវត្ថុគណបក្សនយោបាយក៏ជាបញ្ហាចោទមួយដែរ។ប្រទេសឥណ្ឌូនេស៊ីបានបញ្ញត្តិនូវបទបញ្ញាទាក់ទងនឹងហិរញ្ញវត្ថុគណបក្សនយោបាយ ស្របពេលនឹងការបង្កើតច្បាប់គណបក្សនយោបាយ និងការកែប្រែការបោះឆ្នោតដើម្បីឆ្លើយតបនឹងភាពជាក់ស្តែងនៃនយោបាយ។ ទោះបីជាបទបញ្ញាថ្មីនេះ បានកំណត់ពីកំរិតនៃវិភាគទានទៅកាន់គណបក្សនយោបាយ និងតំរូវឲ្យគណបក្សនយោបាយធ្វើនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនក៏ដោយ ក៏មិនមានការបែងចែកច្បាស់អំពីហិរញ្ញវត្ថុគណបក្សនយោបាយ និងហិរញ្ញវត្ថុសំរាប់យុទ្ធនាការឃោសនាបោះឆ្នោតនោះទេ ហើយជាងនេះទៅទៀតក៏មិនមានការកំណត់ឲ្យបានច្បាស់លាស់ផងដែរនូវរយៈពេលនៃយុទ្ធនាការបោះឆ្នោត។ ដូច្នេះបេក្ខជនគណបក្សនយោបាយព្រមទាំងអ្នកអង្កេតការណ៍តែងតែមានការយល់ច្រឡំអំពីអ្វីដែលច្បាប់អនុញ្ញាតនិងអ្វីដែលច្បាប់ហាមឃាត់។



**ការគ្រប់គ្រងហិរញ្ញវត្ថុនយោបាយនៅឥណ្ឌូនេស៊ី** ផ្តោតសំខាន់ទៅលើការគ្រប់គ្រងហិរញ្ញវត្ថុសំរាប់យុទ្ធនាការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ សំរាប់ការបោះឆ្នោតនៅឥណ្ឌូនេស៊ីដោយអនុលោមតាមមាត្រាខ្លះនៃច្បាប់ ស្តីពីការបោះឆ្នោតទូទៅនៃគណបក្សនយោបាយ។

## បញ្ហាច្បាប់ និងយុត្តាធិការ

ការគ្រប់គ្រង និងធ្វើរបាយការណ៍ហិរញ្ញវត្ថុគណបក្សនយោបាយនៅក្នុងប្រទេសឥណ្ឌូនេស៊ីជាបន្ទុករបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(KPU) តែក្នុងអំឡុងពេលឃោសនាបោះឆ្នោតប៉ុណ្ណោះ។ ច្បាប់លេខ២ឆ្នាំ១៩៩៩ ស្តីពីគណបក្សនយោបាយបានផ្តល់អំណាចទូទៅទៅឲ្យតុលាការកំពូលនៃសាធារណរដ្ឋឥណ្ឌូនេស៊ីក្នុងការត្រួតពិនិត្យ និងពង្រឹងការអនុវត្តន៍បទបញ្ញានៃគណបក្សនយោបាយ។ ជំពូក៦នៃច្បាប់នេះដែរ ក៏បានបញ្ញត្តិមាត្រាមួយចំនួនស្តីពីហិរញ្ញវត្ថុគណបក្សនយោបាយផងដែរ។ ច្បាប់នេះបានចែងក្នុងមាត្រានូវដែនកំណត់នៃប្រភព និងចំនួនទឹកប្រាក់ដែលអាចធ្វើជាអំណោចដល់គណបក្សនយោបាយ និងតំរូវឲ្យគណបក្សនយោបាយធ្វើនូវរបាយការណ៍អំពីសកម្មភាពហិរញ្ញវត្ថុរបស់ខ្លួនទៅកាន់តុលាការកំពូល។ របាយការណ៍របស់IFES ដែលនិយាយអំពីថវិកានយោបាយបានកត់សំគាល់នូវចំនុចរួម និងភាពមិនស្របគ្នានៃការគ្រប់គ្រងហិរញ្ញវត្ថុគណបក្សកំណត់ដោយច្បាប់ ស្តីអំពីគណបក្សនយោបាយ និងច្បាប់ស្តីការបោះឆ្នោតទូទៅ(ច្បាប់លេខ២ និងច្បាប់លេខ៣) អញ្ញមញ្ញភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុគណបក្សនយោបាយ សំរាប់ការឃោសនាបោះឆ្នោតដែលកំណត់ដោយច្បាប់បោះឆ្នោត និងការគ្រប់គ្រងសកម្មភាពហិរញ្ញវត្ថុនៃគណបក្សនយោបាយកំណត់ដោយច្បាប់ ស្តីគណបក្សនយោបាយនៅមានភាពមិនច្បាស់លាស់នៅឡើយ។ យ៉ាងណាមិញ មានការពន្យល់បន្ថែមនៅក្នុងច្បាប់បោះឆ្នោតដែលបែងចែកថវិកាគណបក្សនយោបាយ ច្បាប់ទាំងពីរនេះសុទ្ធតែតំរូវឲ្យគណបក្សនយោបាយធ្វើនូវរបាយការណ៍ហិរញ្ញវត្ថុ មុនពេលបោះឆ្នោត១៥ថ្ងៃមុនពេលបោះឆ្នោត។ តែមាននូវភាពមិនស្របគ្នា



មួយត្រូវបានកត់សំគាល់រវាងរបបក្នុងការធ្វើរបាយការណ៍កំណត់ដោយច្បាប់ ស្តីពីគណបក្សនយោបាយ និងរបាយការណ៍ក្រោយពេលបោះឆ្នោតតំរូវដោយច្បាប់បោះឆ្នោត។ ច្បាប់គណបក្សនយោបាយតំរូវឲ្យគណបក្សនយោបាយធ្វើរបាយការណ៍ហិរញ្ញវត្ថុ៣០ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត ចំណែកឯច្បាប់បោះឆ្នោតវិញតំរូវឲ្យគណបក្សនយោបាយធ្វើរបាយការណ៍ហិរញ្ញវត្ថុ២៥ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត។ មាត្រា១៥នៃច្បាប់ ស្តីពីគណបក្សនយោបាយក៏បានរាប់បញ្ចូលផងដែរនូវកាតព្វកិច្ចរបស់គណបក្សនយោបាយក្នុងការធ្វើរបាយការណ៍ប្រចាំឆ្នាំ។





## អំណាចដាក់ទណ្ឌកម្មចំពោះគណបក្សនយោបាយ

ច្បាប់ស្តីពីគណបក្សនយោបាយ បានផ្តល់អំណាចទៅឲ្យតុលាការក្នុងការដាក់ទណ្ឌកម្មដូចជាៈ

១. តុលាការកំពូលនៃសាធារណរដ្ឋឥណ្ឌូនេស៊ី ដាក់ទណ្ឌកម្មរដ្ឋបាលក្រោមរូបភាពជាការផ្អាកវិភាគទានរបស់រដ្ឋទៅឲ្យគណបក្សនយោបាយ បើគណបក្សនយោបាយត្រូវបានរកឃើញថា បានបំពានទៅលើមាត្រា១៥ នៃច្បាប់នេះ។

២. តុលាការកំពូលនៃសាធារណរដ្ឋឥណ្ឌូនេស៊ី ដកសិទ្ធិចូលរួមក្នុងការបោះឆ្នោតរបស់គណបក្សនយោបាយ បើគណបក្សនយោបាយមិនគោរពតាមមាត្រា១៣ និង១៤ដែលហាមឃាត់ការធ្វើពាណិជ្ជកិច្ចរបស់គណបក្សនយោបាយ កំណត់ពីកំរិតនៃវិភាគទានចូលគណបក្ស និងតំរូវឲ្យគណបក្សមានរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន។

៣. ការដកហូតសិទ្ធិដូចដែលបានចែងក្នុងចំណុចខាងលើ ធ្វើឡើងបន្ទាប់ពីស្តាប់ការពិចារណារបស់គណបក្សនយោបាយ និងតុលាការកំពូល។

## ប្រតិបត្តិការក្នុងអំឡុងពេលបោះឆ្នោតឆ្នាំ១៩៩៩

បញ្ហាទាក់ទិននឹងការគ្រប់គ្រងនិងការផ្សព្វផ្សាយហិរញ្ញវត្ថុគណបក្សនយោបាយនាសម័យបោះឆ្នោតឆ្នាំ១៩៩៩នៅឥណ្ឌូនេស៊ី បានឆ្លុះបញ្ចាំងឲ្យឃើញនូវភាពមិនច្បាស់លាស់នៃទំនួលខុសត្រូវផ្នែកយុត្តាធិការកំណត់ដោយច្បាប់នយោបាយថ្មី ក៏ដូចជាផ្នែករដ្ឋបាលដែលខ្វះបទពិសោធន៍ក្នុងវិស័យនេះដែរ។ តុលាការកំពូលមើលទៅហាក់ដូចជា មានកតព្វកិច្ចកំណត់នូវគោលការណ៍រដ្ឋបាល និងកាន់តួនាទីរបស់ខ្លួនតាមការកំណត់នៃច្បាប់គណបក្សនយោបាយ ដែលសមត្ថកិច្ចនេះមានផងដែរចំពោះយុទ្ធនាការឃោសនាបោះឆ្នោត។






នៅថ្ងៃទី២០ មីនា ឆ្នាំ១៩៩៩ តុលាការកំពូលចេញនូវសេចក្តីសំរេចមួយដែលកំណត់ពីបទបញ្ញាសំរាប់ត្រួតពិនិត្យគណបក្សនយោបាយ និងអំណាចរបស់ខ្លួនក្នុងការដាក់ទណ្ឌកម្មទៅលើគណបក្សនយោបាយក្នុងករណីបំពានច្បាប់គណបក្សនយោបាយ។ បទបញ្ញានេះកំណត់ផងដែរនូវទំរង់របាយការណ៍សកម្មភាពហិរញ្ញវត្ថុគណបក្សនយោបាយ បង្កាន់ដៃអំណោយដែលបានទទួលនិងចំណាយ។ ផ្ទុយទៅវិញបទបញ្ញាដែលចេញពីសេចក្តីសំរេចរបស់តុលាការកំពូលនេះមិនមាន កំលាំងគតិយុត្តចាប់បង្ខំដល់គណបក្សនយោបាយនោះទេ ចំណែកគណបក្សនយោបាយវិញ ក៏ហាក់ដូចជាមិនបានទទួលស្គាល់កាតព្វកិច្ចធ្វើរបាយការណ៍ហិរញ្ញវត្ថុ សំរាប់យុទ្ធនាការឃោសនាបោះឆ្នោតនេះទៅឲ្យតុលាការកំពូលដែរ។ តែចុងក្រោយ ដោយមិនចាំបាច់មានការកំណត់ដោយច្បាប់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឥណ្ឌូនេស៊ី (KPU) បានសម្រុះសម្រួលការធ្វើរបាយការណ៍ហិរញ្ញវត្ថុទាំងពីរដែលកំណត់ដោយច្បាប់បោះឆ្នោត និងច្បាប់ស្តីពីគណបក្សនយោបាយដោយមិនខ្វល់ពីកាលកំណត់នៃរបាយការណ៍ដែលចែងដោយច្បាប់ទាំងពីរខាងលើ ហើយដោយថតចំលងរបាយការណ៍ហិរញ្ញវត្ថុសំរាប់យុទ្ធនាការឃោសនាបោះឆ្នោត ដែលគណបក្សនយោបាយផ្ញើមកឲ្យរួចផ្ញើទៅតុលាការកំពូល។







ដូច្នេះក្នុងករណីនេះKPU រុញនូវបន្ទុកក្នុងការស៊ើបអង្កេត និងការដាក់ទណ្ឌកម្មចំពោះការមិនគោរព ឬរំលោភបំពានទាក់ទិននឹងការធ្វើរបាយការណ៍ហិរញ្ញវត្ថុនេះទៅឲ្យតុលាការកំពូល។ ដើម្បីអនុវត្តតួនាទីដែលកំណត់ដោយច្បាប់គណបក្សនយោបាយនេះ តុលាការកំពូលនៃសាធារណរដ្ឋឥណ្ឌូនេស៊ីបានបង្កើតនូវនាយកដ្ឋានមួយដែលទទួលបន្ទុកការងារនយោបាយ។ នាយកដ្ឋាននេះមានសមាជិក៦នាក់ រាប់បញ្ចូលទាំងនាយកផងដែរ។ នាយកត្រូវធ្វើរបាយការណ៍ទៅឲ្យបញ្ជិការ ដែលជាអគ្គលេខាធិកានៃតុលាការកំពូល។ ជាគោលការណ៍នាយកមានតួនាទីបញ្ជូននូវករណីដែលកើតឡើងពីការគ្រប់គ្រងគណបក្សនយោបាយទៅកាន់បញ្ជិការ។ នាយកមានតួនាទីសង្ខេបរបាយការណ៍ហិរញ្ញវត្ថុដែលទទួលបានពីគណបក្សនយោបាយ ហើយផ្ញើបន្តនូវសេចក្តីត្រួតពិនិត្យរបស់ខ្លួនទៅឲ្យបញ្ជិការនៃតុលាការ។

យោងតាមច្បាប់ ស្តីពីគណបក្សនយោបាយ របាយការណ៍ហិរញ្ញវត្ថុរបស់គណបក្សនយោបាយ គួរតែត្រូវបានត្រួតពិនិត្យដោយហិរញ្ញិកសាធារណៈតែងតាំងដោយតុលាការកំពូល។ ជាអកុសល តុលាការកំពូលមិនមានថវិកាគ្រប់គ្រាន់ ដើម្បីជួលគណនេយ្យករនោះទេ។ យ៉ាងណាក៏ដោយ ទោះជាតុលាការជួលគណនេយ្យករក៏តួនាទីរបស់គណនេយ្យករនេះមានកំរិតត្រឹមការត្រួតពិនិត្យថាតើថវិកាដែលទទួលនិងចំណាយដោយគណបក្សនយោបាយត្រឹមត្រូវតាមការកំណត់ ដោយច្បាប់ដែរឬទេដោយយោងតាមពត៌មានដែលបានផ្តល់ឲ្យតាមរបាយការណ៍។ ដោយសារការខ្វះនូវរូបមន្តគណនាច្បាស់លាស់ និងការទទួលស្គាល់នូវអំណោយមិនស្របច្បាប់ និងការចំណាយមិនត្រឹមត្រូវមួយចំនួន តុលាការកំពូលមិនទំនងជាអាចលាតត្រដាងពីការបំពានទៅលើបទបញ្ញត្តិដែលចែងពីហិរញ្ញវត្ថុគណបក្សនយោបាយនៃច្បាប់ ស្តីពីគណបក្សនយោបាយនោះទេ។ ដូច្នេះច្បាប់ស្តីពីគណបក្សនយោបាយ បានផ្តល់នូវសក្តានុពលសំរាប់ការពិនិត្យពិច័យបញ្ជីហិរញ្ញវត្ថុគណបក្សនយោបាយតិចជាងបទបញ្ញត្តិ ស្តីពីហិរញ្ញវត្ថុសំរាប់យុទ្ធនាការឃោសនាបោះឆ្នោតនៃច្បាប់បោះឆ្នោត។ ក្នុងឆ្នាំ១៩៩៩ សំរាប់របាយការណ៍មុននិងក្រោយការបោះឆ្នោត KPU បានតែងតាំងគណនេយ្យករសាធារណៈសំរាប់គណបក្សនយោបាយនីមួយៗ ដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត ដើម្បីត្រួតពិនិត្យរបាយការណ៍របស់ពួកគេ។ យ៉ាងណាមិញការងាររបស់គណនេយ្យករនេះមិនសូវជាមានប្រសិទ្ធិភាពនោះទេ ដោយរបាយការណ៍របស់គណបក្សនយោបាយតែងតែមិនមានលក្ខណៈល្អិតល្អន់ ហើយតែងតែមិនភ្ជាប់នូវឯកសារយោង។ ដូច្នេះវាគ្រាន់ជាការត្រួតពិនិត្យទៅលើភាពមិនសមស្រប ឬការបំពានច្បាប់ប៉ុណ្ណោះ តែគណនេយ្យករមិនមានអំណាចដើម្បីស៊ើបអង្កេត លើបញ្ហាទាំងនេះ និងទាមទារឯកសារបន្ថែមនោះទេ។ ចំណែកតុលាការកំពូលវិញ ទោះជាតុលាការជួលគណនេយ្យករសាធារណៈ ដើម្បីពិនិត្យបញ្ជីរបាយការណ៍គណបក្សនយោបាយក៏ដោយ នាយក ដ្ឋានទទួលបន្ទុកកិច្ចការនយោបាយនៅក្នុងតុលាការ ហាក់ដូចជាគ្មានអំណាចឯករាជ្យដើម្បីប្តឹងគណបក្សនយោបាយដែលបានរំលោភបំពានច្បាប់នោះទេ។ ករណីនេះតុលាការបែរជារង់ចាំបណ្តឹងពីខាងក្រៅទៅវិញ។



តុលាការសំរួលដល់សាធារណជន ក្នុងការត្រួតពិនិត្យរបាយការណ៍គណបក្សនយោបាយតាមរយៈការសរសេរសំណើរទៅអគ្គលេខាធិការតុលាការ។ ក៏ប៉ុន្តែមិនមាននូវយន្តសាស្ត្រក្នុងការផ្សព្វផ្សាយជាសាធារណៈ និងការកាត់សេចក្តីលើបណ្តឹងណាមួយត្រូវបានធ្វើដោយតុលាការនៅឡើយទេ ដោយសារមិនទាន់មានបុគ្គលគណបក្សនយោបាយ ឬអ្នកយកសារពត៌មានណាមួយបានស្នើសុំទៅតុលាការ ដើម្បីត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុគណបក្សនយោបាយនៅឡើយ។ បច្ចុប្បន្នតួនាទីរដ្ឋបាលរបស់តុលាការកំពូលក្នុងការត្រួតពិនិត្យហិរញ្ញវត្ថុគណបក្សនយោបាយនៅមានកំរិត។


ការផ្សាយរបស់គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌

# កាលប្បវត្តិព្រឹត្តិការណ៍សំខាន់ៗ

ពីខែកញ្ញា ដល់ខែតុលា ឆ្នាំ២០១០

## នយោបាយ និងសង្គម




- ៣០ កញ្ញា ២០១០ ៖ បន្ទាប់ពីកាសែត មេគង្គ (Mekong) ដែលបានក្ស័យធន ក្នុងឆ្នាំ ១៩៩៥ កាសែតបារាំង កាំបូដ ស័រ (Cambodge Soir) បានប្រកាសបិទទ្វារត្រឹមខែកញ្ញា ឆ្នាំ២០១០នេះ ដោយមូលហេតុនៃការឈប់ផ្សាយត្រូវបាន និពន្ធនាយកកាសែត លោក ប៉ែន បូណា បញ្ជាក់ឲ្យដឹងថា ក្ស័យធន។ កាសែតមួយនេះ មាន បុគ្គលិកសរុប ៣០ នាក់ រាប់បញ្ចូលទាំងអ្នកយកព័ត៌មានមានជនជាតិខ្មែរ ៥ នាក់ និងជនជាតិបារាំង ៥ នាក់។



- ១ តុលា ២០១០ ៖ ប៉ូលិសចរាចរណ៍ជើងគោកចាប់ផ្តើមអនុវត្តការផាកពិន័យចំពោះអ្នកបើកបរយានយន្តតាមផ្លូវសាធារណៈ ដែលទទួលទានសុរាច្រើនហួសច្បាប់កំណត់។ ច្បាប់ស្តីពី ចរាចរណ៍ជើងគោក ឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា បានកំណត់ការផាកពិន័យដល់អ្នកបើកបរយានយន្តទាំងឡាយណា ដែលបើកបរមានជាតិស្រា ឬអាល់កុល ចាប់ពី ២៥ ០០០ (ពីរម៉ឺនប្រាំពាន់) រៀល ទៅដល់ ១ ០០០ ០០០ (មួយលាន) រៀល ករណីពិនិត្យជាតិអាល់កុលឃើញមានចាប់ពី ០.៤០ មីលីក្រាម ក្នុងមួយលីត្រខ្យល់ ឬចាប់ពី ០.៨ ក្រាមក្នុងមួយលីត្រឈាមឡើងទៅ។ ច្បាប់ចរាចរណ៍ ក៏អាចនឹងផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ៦ (ប្រាំមួយ) ខែ ចំពោះបទល្មើសលហុជដែលនេះផងដែរ។



- ២១ តុលា ២០១០ ៖ តំណាងរាស្ត្រសភាសហភាពអឺរ៉ុប បានស្នើឲ្យសហភាពអឺរ៉ុប ជាប្រទេសម្ចាស់ជំនួយកម្ពុជា ចាត់វិធានការបង្ខំឲ្យរដ្ឋាភិបាលកម្ពុជាគោរពសិទ្ធិមនុស្ស ហើយបានស្នើឲ្យរដ្ឋាភិបាលកម្ពុជា ប្រគល់អភ័យឯកសិទ្ធិសភា ឲ្យលោក សម រង្ស៊ី វិញ ដើម្បីឲ្យតំណាងរាស្ត្រគណបក្សជំទាស់រូបនេះ អាចវិលត្រឡប់មកកម្ពុជា ពិសេសចូលរួមការបោះឆ្នោតឃុំ សង្កាត់ ឆ្នាំ២០១២ និងការបោះឆ្នោតសកលឆ្នាំ២០១៣។ សភាសហភាពអឺរ៉ុប ចាត់ទុកថាការដកហូតអភ័យឯកសិទ្ធិ និងការកាត់ទោសលោក សម រង្ស៊ី ជារឿងនយោបាយ ហើយអាចបណ្តាលឲ្យគ្រោះថ្នាក់ដល់ដំណើរការប្រជាធិបតេយ្យសម្រាប់កម្ពុជា។
- ២៣ តុលា ២០១០ ៖ ក្នុងឱកាសខួបលើកទី ១៩ នៃការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានផ្ញើលិខិតមួយច្បាប់ទៅកាន់ប្រធានរដ្ឋសភាជាតិ ដោយបាន បដិសេធន៍មិនឆ្លើយនឹងសំណួររបស់អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ី ហើយបានបង្វែរឲ្យប្តឹងទៅកាន់តុលាការ ទាក់ទងនឹង ការចោទថារដ្ឋាភិបាលកម្ពុជាបានលូកដៃចូលក្នុងកិច្ចការផ្ទៃក្នុងរបស់ថៃតាមរយៈការតែងតាំងលោកថាក់ស៊ីន អតីតនាយករដ្ឋមន្ត្រីថៃ ឲ្យធ្វើជាទីប្រឹក្សាសេដ្ឋកិច្ចរបស់រដ្ឋាភិបាល និងសំណួរ«តើហេតុអ្វីបានជារដ្ឋាភិបាលរំលោភកិច្ចព្រមព្រៀងក្រុងប៉ារីសក្នុងការបណ្តោយឲ្យថៃឈ្លានពានទឹកដីកម្ពុជា?




- ១ វិច្ឆិកា ២០១០ ៖ នៅក្នុងដំណើរទស្សនកិច្ចផ្លូវការនៅកម្ពុជា ចាប់ពីថ្ងៃទី៣០ តុលា ដល់ថ្ងៃទី ១ វិច្ឆិកា ឆ្នាំ២០១០ លោកស្រី ហ៊ីលឡារី គ្លីនតុន ( Hillary Clinton ) រដ្ឋមន្ត្រីការបរទេសអាមេរិក បានបញ្ជាក់ក្នុងសន្និសីទកាសែត ថា សហរដ្ឋអាមេរិកនឹងបន្តផ្តល់ជំនួយបន្ថែមទៀត សម្រាប់ដំណើរការកាត់ទោសខ្មែរក្រហម ខណៈដែលបំណុលជាង ៣០០ លានដុល្លារសហរដ្ឋ ដែលកម្ពុជាជំពាក់សហរដ្ឋអាមេរិក តាំងពីសម័យ លន់ នល់ អាមេរិកកំពុងតែពិចារណាដើម្បីលុបបំណុល តាមវិធីផ្ទេរបំណុលទៅជាជំនួយអភិវឌ្ឍ តែលោកស្រីចង់ឃើញ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ផ្នែកសិទ្ធិមនុស្ស បន្តដំណើរការនៅកម្ពុជាបន្តទៀត។ ការដាក់លក្ខខណ្ឌបែបនេះ ធ្វើឡើងដើម្បីឆ្លើយតបទៅនឹងកិច្ចជំនួបថ្ងៃទី ២៧ តុលា ២០១០ រវាង លោកនាយករដ្ឋមន្ត្រីកម្ពុជា ហ៊ុន សែន និង លោក បាន គីមូន (Ban Ki-moon) អគ្គលេខាធិការរបស់អង្គការសហប្រជាជាតិ ដែលបានស្នើឲ្យដកលោក គ្រីស្តូហ្វ ប៉េស៊ូ (Christophe Peschoux) ចេញពីតំណែង ជាប្រធាន ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ហើយបិទការិយាល័យជាក្រោយ ដោយហេតុផល ប្រធានការិយាល័យ រូបនេះ មិនមានកិច្ចសហប្រតិបត្តិការល្អជាមួយនឹងរដ្ឋាភិបាល ហើយបែរជាដើរតួជាអ្នកនាំពាក្យឲ្យគណបក្សប្រឆាំងក្នុងប្រទេសកម្ពុជា។ នៅក្នុងសន្និសីទកាសែតរួមគ្នានៅថ្ងៃទី១ ខែវិច្ឆិកា រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជា លោក ហោ ណាំហុង បានបញ្ជាក់ថាការស្នើនោះមិនទាន់មានជាការសម្រេចចិត្តណាមួយនៅឡើយទេ។





## សិទ្ធិមនុស្ស និងប្រជាធិបតេយ្យ




- ២៨ កញ្ញា ២០១០ ៖ លោក ស៊ូយ៉ា ស៊ូប៉ែឌី បានថ្លែងនៅក្នុង សម័យប្រជុំលើកទី ១៥ នៃក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិថា ការអនុវត្តច្បាប់នៅប្រទេសកម្ពុជា មិនមានសមាមាត្រទេ ពិសេសពាក់ ពន្ធ័នឹងការ បរិហារកេរ្តិ៍ និងការផ្សព្វផ្សាយព័ត៌មានមិនពិត ចំពោះអ្នកកាសែតសកម្មជនសិទ្ធិមនុស្ស និងមេដឹក នាំនយោបាយមួយចំនួន។ លោក ក៏បានផ្តល់អនុសាសន៍ មួយចំនួន ដើម្បីពង្រឹងប្រពន្ធ័តុលាការឲ្យមានឯករាជ្យ និងលើកស្ទួយការគោរពសិទ្ធិមនុស្សនៅកម្ពុជា តែ ឯកអគ្គរាជទូតកម្ពុជា ប្រចាំអង្គការសហប្រជាជាតិ បានពន្យល់ថា កម្ពុជាបានចាត់វិធានការដើម្បីដោះស្រាយបញ្ហាសិទ្ធិមនុស្សទាំងនោះរួចហើយ ក្នុងការកំណែ ទម្រង់ច្បាប់ និងប្រពន្ធ័តុលាការ ហើយក៏បានកំពុងបង្កើនល្បឿនក្នុងការតាក់តែងច្បាប់នានាផងដែរ។

## ច្បាប់ និងតុលាការ



- ២៨ កញ្ញា ២០១០ ៖ ក្នុងសិក្ខាសាលាមួយស្តីពី ការចែករំលែកបទពិសោធន៍ដោះស្រាយវិវាទក្រៅប្រពន្ធ័ ក្រៅប្រពន្ធ័តុលាការ ក្រោមគម្រោងសិទ្ធិទទួលបានយុត្តិធម៌ នៅសណ្ឋាគារ កាំបូឌីយ៉ាណា មន្ត្រីជាន់ខ្ពស់នៃក្រ សួងមហាផ្ទៃ បានថ្លែងឲ្យដឹងថា ក្រសួងមហាផ្ទៃបានបង្កើតមណ្ឌលសេវាកម្មយុត្តិធម៌ ថ្នាក់ស្រុក ក្រុង ដើម្បី ដោះស្រាយជម្លោះតូចតាច ២០ ទីតាំងនៅតាមបណ្តាខេត្តចំនួន ៦ ។ មណ្ឌលសេវាកម្មយុត្តិធម៌ក្នុងការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការទាំងនេះ នឹងជួយឲ្យប្រជាពលរដ្ឋទទួលបានយុត្តិធម៌ ចំណេញពេលវេលា និងថវិកាចំពោះករណីជម្លោះតូចតាច ដូចជាករណីទំនាស់ដីធ្លី បរិហារកេរ្តិ៍ ឬជេរប្រមាថ អំពើហិង្សាក្នុងគ្រួសារ ជំពាក់ប្រាក់ លែងលះ មរតក ធ្វើឲ្យខូចខាតទ្រព្យសម្បត្តិ ទំនាស់បិទផ្លូវ និងព្រំដីទាមទារអាហារកិច្ចចិញ្ចឹមកូន ផ្តាច់ពាក្យរៀបអាពាហ៍ពិពាហ៍។ល។ ប្រធានក្រុមប្រឹក្សានីតិកម្មនៃក្រសួងមហាផ្ទៃ លោក ផុន ប៊ុនថាល់ បានបន្ថែមថា ក្រសួងក៏ចង់បង្កើតមណ្ឌលសេវាកម្មយុត្តិធម៌បែបនេះ នៅគ្រប់ខេត្តក្រុង





ការផ្សាយរបស់គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌

ប្រសិនបើមានថវិកាគាំទ្រ។

»» ២១ តុលា ២០១០ ៖ ឯកឧត្តម កឹម សុខា ប្រធានគណបក្សសិទ្ធិមនុស្ស និងជាអតីតប្រធានមជ្ឈមណ្ឌលសិទ្ធិ មនុស្សកម្ពុជា ត្រូវបានតុលាការសាលារាជធានីភ្នំពេញ អញ្ជើញឲ្យទៅបំភ្លឺ ក្នុងបណ្ដឹងពីរ ពាក់ពន្ធ័នឹង **ការក្លែងបន្លំឯកសារ និងការរំលោភលើសេចក្ដីទុកចិត្ត** ក្នុងឆ្នាំ ២០០៦ ។ លោក សារិន សាន់ និង លោក ឈឹម ផលវ៉ុន ដែលតាំងខ្លួនជាដើមបណ្ដឹង ហើយបានស្នើឲ្យតុលាការដំណើរការលើសំណុំរឿងដែលផ្អឹបទុករាប់ឆ្នាំនេះ បានចោទប្រកាន់ថា លោក កឹម សុខា បានបំបាត់ប្រាក់បៀវត្សរ៍មិនបើកឲ្យគ្រប់ចំនួន និងគែបន្លំយកប្រាក់ ថ្លៃទូរសព្ទ័ដោយប្រើប្រាស់ហត្ថលេខាបន្លំ ។ នៅសម័យអន្តរកាល សវនកររបស់ម្ចាស់ជំនួយធ្លាប់បានបញ្ជាក់ថា លោក កឹម សុខា មិនបានពាក់ពន្ធ័នឹងរឿងអាស្រូវទាំងនេះទេ។



## អភិបាលកិច្ច និងការអភិវឌ្ឍ

»» ២០ កញ្ញា ២០១០ ៖ ស្ពានព្រែកព្នៅ ប្រវែង ៩. ៩៦២ ម៉ែត្រ និងទទឹង ១៤ ម៉ែត្រ ស្ថិតនៅឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្ដាល ដែលចំណាយថវិកា សាងសង់អស់ប្រមាណ ៤៣.៥៥០.០០០ ដុល្លារសហរដ្ឋអាមេរិក ត្រូវបានលោក នាយករដ្ឋមន្ត្រី ហ៊ុន សែន សម្ពោធប្រកាសឲ្យប្រើប្រាស់ ហើយ វិនិយោគឲ្យ ក្រុមហ៊ុនឯកជន អិល វ៉ៃ ភី (L.Y.P Group) របស់លោកឧកញ៉ា លី យ៉ុងផាត់ រយៈពេល ៣០ ឆ្នាំ។ ក្រោយពេលសម្ពោធស្ពានព្រែកព្នៅនេះតទៅ សាលាក្រុងភ្នំពេញ បានប្រកាសហាមមិនឲ្យរថយន្តធុនធំឆ្លងកាត់ស្ពានជ្រោយចង្វាទៀតទេ ហើយដើម្បីឆ្លងកាត់ស្ពាននេះ យានយន្តទាំងឡាយ ចាប់ពីប្រទេសរថយន្តតាក់ស៊ីធុនតូច/ទេសចរណ៍ រហូតដល់រថយន្តដឹកជញ្ជូនលើសពី កង់ ១០ តម្រូវឲ្យបង់ប្រាក់ចាប់ពី ៥ ៧០០ រៀល រហូតដល់ ៣៤ ០០០ រៀល លើកលែងអ្នកធ្វើដំណើរតាម មធ្យោបាយទោចក្រយាន្ត និងថ្មើរជើងមិនតម្រូវឲ្យបង់ប្រាក់។




»» ២២ កញ្ញា ២០១០ ៖ ក្រុមហ៊ុនថតកុនហូលីវូដរបស់សហរដ្ឋអាមេរិកមួយ ដែលដឹកនាំដោយ លោក តាម៉ាស ម៉ាហ្គយ៉ា (Tamas Magyar) គ្រោងនឹងផលិតភាពយន្តខ្នាតធំ ក្រោមចំណងជើងថា មហាអធិរាជខ្មែរ (Great Khmer Empire) ចាប់ពីដើមឆ្នាំ ២០១១ ដល់ឆ្នាំ ២០១៣ នៅក្នុងទឹកដីអង្គរប្រទេសកម្ពុជា ដោយចំណាយថវិកាប្រមាណ ៧០ លាន ដុល្លារសហរដ្ឋអាមេរិក។ តារា ហូលីវូដ លោក ថូនី សេណា (Tony Schiena) អ្នកនាង អាន់ជេលីណា ជូលី (Angelina Jolie) លោក ជេត លី អ្នកនាង ហ៊ាន់ ជីអ៊ុន និងតារាភាពយន្តខ្មែរមួយចំនួន នឹងត្រូវបានអញ្ជើញឲ្យចូលរួមជាតួសម្ដែង។



»» ១៩ តុលា ២០១០ ៖ អគារទីស្ដីការនាយករដ្ឋមន្ត្រី ដែលជាការិយាល័យសម្រាប់នាយករដ្ឋមន្ត្រីធ្វើការ ហើយបំពាក់ទៅដោយប្រពន្ធ័ការពារភេរវកម្ម និងត្រួតពិនិត្យខ្ពស់ មានកាម៉េរ៉ាតាមដានសកម្មភាពរាប់រយគ្រឿង ប្រពន្ធ័ផ្ដាច់សេវាទូរសព្ទ័ ត្រូវបានប្រកាសឲ្យប្រើប្រាស់ ដោយនាយករដ្ឋមន្ត្រីកម្ពុជា ហ៊ុន សែន និងប្រសិទ្ធិនាមថា អគារសន្តិភាព។ អគារនេះ ប្រើប្រាស់ថវិកាជាតិទាំងស្រុង តែមិនបានប្រកាសថា ចំណាយអស់ទឹកប្រាក់ប៉ុន្មានក្នុងការសាងសង់ទេ គ្រាន់តែបង្ហាញជាសាធារណៈថា អគារទីស្ដីការនាយករដ្ឋមន្ត្រី មានកម្ពស់ ៥ ជាន់ និងមានទំហំធិត ២ ដង នៃអគារទីស្ដីការគណៈរដ្ឋមន្ត្រី









(អគារទីស្ដីការគណៈរដ្ឋមន្ត្រី សាងសង់អស់ទឹកប្រាក់ប្រមាណ ៣២,៩ លានដុល្លារ) ដែលជាអំណោយរបស់ប្រទេសចិន ហើយបានបើកឲ្យដំណើរការតាំងពីខែកុម្ភៈ ២០០៩។




»» ២១ តុលា ២០១០ ៖ ឃុំចំនួន ២០ ដែលស្ថិតក្នុងស្រុកពញាឮ (៣) ស្រុកអង្គស្នួល (៦) ស្រុកកណ្ដាលស្ទឹង (៥) ស្រុកកៀនស្វាយ (៤) និងស្រុកមុខកំពូល (២) ត្រូវបាន ព្រះមហាក្សត្រខ្មែរ សម្ដេចព្រះបរមនាថ នរោត្តម សីហមុនី ឡាយព្រះហស្ថលេខា លើព្រះរាជក្រឹត្យប្រកាសដាក់បញ្ចូលក្នុងរចនាសម្ព័ន្ធរដ្ឋបាល របស់រាជធានីភ្នំពេញ។

»» ២១ តុលា ២០១០ ៖ ក្រុមហ៊ុនអាកាសចរណ៍បារាំង Air France បានចេញសេចក្ដីប្រកាសព័ត៌មានមួយថា ចាប់ពីថ្ងៃទី ២៧ មីនា ឆ្នាំ ២០១១ ខាងមុខ ក្រុមហ៊ុន Air France នឹងផ្ដើមប្រតិបត្តិការហោះហើរលើកដំបូងរបស់ខ្លួន ចេញដំណើរពីអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ទៅព្រលានយន្តហោះ Charles De Gaulles ទីក្រុងប៉ារីស នៅរៀងរាល់ថ្ងៃអង្គារ ព្រហស្បតិ៍ និងថ្ងៃសៅរ៍ ហើយធ្វើដំណើរត្រឡប់ពីទីក្រុងប៉ារីស មកភ្នំពេញវិញ នៅរៀងរាល់ថ្ងៃចន្ទ ថ្ងៃពុធ និងថ្ងៃសុក្រ។ ការហោះហើរទាំងនេះនឹងត្រូវប្រើប្រាស់ យន្តហោះធុន Airbus A340 ផ្ទុកអ្នកដំណើរបាន២៧៥នាក់ និងយន្តហោះធុន Boeing 777 ដែលអាចផ្ទុកអ្នកដំណើរបានរហូតដល់៣០៩នាក់។






## ឯកសារផលិតដោយ ខុមហ្វ្រែល








### គណៈកម្មការព្រឹត្តិបត្រ

១» លោក **គល់ បញ្ញា** ទីប្រឹក្សាផ្ដល់យោបល់
២» លោក **ចន្ទ័ ដារិទ្ធ** ប្រធានព័ត៌មាន និងការផ្សាយ
៣» លោក **ស្រី សុភក្រ្ត័** អ្នកនិពន្ធ
៤» កញ្ញា **មឿន សុខមុនី** លេខាការផ្សាយព្រឹត្តិបត្រ

អាសយដ្ឋាន៖ ផ្ទះលេខ១៣៩ ផ្លូវ.១២១ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទ័ ៖ ០២៣ ៨៨៤ ១៥០
ទូរសារ ៖ ០២៣ ៨៨៣ ៧៥០
អ៊ីម៉ែល ៖ comfrel@online.com.kh
គេហទំព័រ ៖ www.comfrel.org
ប្រអប់សំបុត្រ ៖ ១១៤៥


### សេចក្ដីជូនដំណឹង

ព្រឹត្តិបត្រ **អ្នកឃ្លាំមើល** នឹងចែកជូនទៅដល់ប្រជាពលរដ្ឋ (ឥត គិត ថ្លៃ) នៅទូទាំងប្រទេសកម្ពុជា ដើម្បីបំពេញចន្លោះព័ត៌មានរវាងប្រជាពលរដ្ឋ និងអ្នកតំណាងរាស្ត្រ អ្នកដឹកនាំ ដែលពាក់ពន្ធ័ក្នុងការចូលរួមស្ថាបនា និងអភិវឌ្ឍសង្គមប្រជាធិបតេយ្យ។

ប្រសិនបើលោក អ្នកនាង កញ្ញា មានសំណូមពរ ឬបំណងចូលរួមយោបល់ ឬស្នើសុំព្រឹត្តិបត្រ និងឯកសារ ផ្សេងៗ ដែលផលិតដោយ ខុមហ្វ្រែល សម្រាប់រក្សាទុក សូមទំនាក់ទំនងមកការិយាល័យខុមហ្វ្រែល តាមអាសយដ្ឋានដូចដែលបានផ្ដល់ជូននេះ យើងខ្ញុំនឹងដោះស្រាយជូននូវរាល់បញ្ហារបស់លោក អ្នកនាង កញ្ញា ដោយមេត្រីភាព។

សូមអរគុណ !